# ពិធីបុណ្យទំនៀមទម្លាប់ ប្រពៃណីជនជាតិចិន

# 中国的年节民俗





វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា

ភ្នំពេញ ២០១១

# មាតិកា


ជំពូកទី ១ ៖ ពិធីបុណ្យសំខាន់ៗ

-ទីមួយ ៖ បុណ្យចូលឆ្នាំចិន....................................០១
-ទីពីរ ៖ បុណ្យឆេងម៉េង....................................០៨
-ទីបី ៖ បុណ្យសែននំចាំង....................................០៨
-ទីបួន ៖ បុណ្យឈីស៊ីថ្ងៃ៧ ខែ៧ចិន....................................០៩
-ទីប្រាំ ៖ បុណ្យសែនលោកខែ....................................១០
-ទីប្រាំមួយ ៖ បុណ្យផុងយ៉ាង.................................... ១២
-ទីប្រាំពីរ ៖ បុណ្យសែននំអ៊ី.................................... ១៣
-ទីប្រាំបី ៖ បុណ្យឡាក់ប៉ាជា....................................១៤

ជំពូកទី ២ ៖ ទំនៀមទម្លាប់ប្រពៃណី

-ទីមួយ ៖ ឆ្នាំសត្វទាំង១២....................................១៥
-ទីពីរ ៖ អក្សរលាភពណ៌ក្រហម១គូ.................... ១៦
-ទីបី ៖ ការអុកឡុកបន្ទប់ផ្សំដំណេក.................... ១៧
-ទីបួន ៖ ចែកស៊ុតក្រហម....................................១៨
-ទីប្រាំ ៖ ពិធី “ជ័រចូវ” .................................... ១៩
-ទីប្រាំមួយ ៖ លុយសង្កត់អាយុ.................................... ១៩
-ទីប្រាំពីរ ៖ ជូនពរខួបកំណើត....................................២០
-ទីប្រាំបី ៖ ការបិទអក្សរលាភបញ្ច្រាស់....................២១
-ទីប្រាំបួន ៖ ការចាក់កាកថ្នាំ.................................... ២២
-ទីដប់ ៖ តំណមមិនឱ្យជាន់ខឿនទ្វារ.................... ២៣
-ទីដប់មួយ ៖ ការដុតក្រដាសសែន.................... ២៣
-ទីដប់ពីរ ៖ ការរាំនាគ....................................២៤
-ទីដប់បី ៖ ការរាំតោ.................................... ២៥
-ទីដប់បួន ៖ វត្ថុសិរីមង្គល.................................... ២៦

ជំពូកទី ៣ ៖ ជំនឿផ្សេងៗ

-ទីមួយ ៖ ហ្វូអ៊ីនីអ៊ារ....................................៣៦
-ទីពីរ ៖ ព្រះម៉ែស៊ីវាំង.................................... ៣៧
-ទីបី ៖ អ្នកតាតុងវ៉ាំង.................................... ៣៧
-ទីបួន ៖ សត្វទេពទាំងបួនក្នុងរឿងព្រេងចិន........... ៣៧
-ទីប្រាំ ៖ ទេវតារក្សាទ្វារ....................................៣៩
-ទីប្រាំមួយ ៖ ទេវតាទ្រព្យ .................................... ៤៣



**ឧត្តមទីប្រឹក្សា**

បណ្ឌិតសភាចារ្យ ខ្លូត ធីតា

បណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន

**ក្រុមត្រួតពិនិត្យ**

លោក វ៉ង ស៊ានមារ

លោក ជា មុនីឫទ្ធិ

**ក្រុមស្រាវជ្រាវ**

ឯកឧត្តមបណ្ឌិត ស៊ុន ហួរ

ឯកឧត្តមបណ្ឌិត គឹម យឿន

លោក ជា ចេងឃុន

លោក អេង មោក្ខ

លោក ទិត្យ រចនា

លោក អ៊ី ឈីហ័រ

លោកស្រី អ៊ី សៃ

កញ្ញា ចាង ឈុនជី

**អ្នកបកប្រែ**

កញ្ញា ដោក ចន្នី

**បច្ចេកទេសកុំព្យូទ័រ**

លោក ប្រា បញ្ញា

## ជំពូកទី ១

# ពិធីបុណ្យសំខាន់ៗ

ប្រវត្តិនៃបុណ្យប្រពៃណីចិនគឺមានតាំងពីយូរលង់ណាស់មកហើយ ពាក្យថាបុណ្យគឺ "**ជៀ**" មានប្រភពមកពីអាកាសធាតុនៅតាមរដូវនីមួយៗតាំងពីបុរាណ។ ពាក្យថាឆ្នាំ ឬ "**នាន**" អត្ថន័យតាំងពីបុរាណមានន័យថាការប្រមូលផលដំណាំមួយលើកផែនដីវិលជុំវិញព្រះអាទិត្យមួយជុំគឺមានរយៈពេលមួយឆ្នាំ។ ក្នុងការបែងចែករដូវតាមច័ន្ទគតិមួយឆ្នាំមាន ៤រដូវ។ ពាក្យថា "**ជៀ**" ន័យដើមគឺសំដៅទៅលើថ្នាំងឬស្សី ក្រោយមកគឺន័យធៀបទៅនឹងលំដាប់ថ្នាក់នៃអាយុថ្ងៃបុណ្យដែលភាសាចិនហៅថា "**ជៀឃីក**" គឺជាពេលកំណត់មួយដែលបង្កើតឡើងដោយការផ្សារភ្ជាប់គ្នារវាងការផ្លាស់ប្តូរអាកាសធាតុនិងថ្ងៃខែឆ្នាំ។ នៅក្នុងកំណត់ត្រាមុនដំបូងគេបង្អស់ក្នុងគម្ពី "**អ៊ីចូវស៊ូ ស៊ីស៊ុន**" ក្នុងមួយឆ្នាំមាន២៤រដូវកាល (ភាសាចិនហៅថា **ជៀឈី**)។

បុណ្យប្រពៃណីរបស់ជនជាតិចិនគឺធ្វើតាមការសែនព្រេនទៅលើថ្ងៃបុណ្យតាមច័ន្ទគតិ ថ្ងៃបុណ្យសាសនា ថ្ងៃបុណ្យប្រពៃណីជនជាតិដែលចេះតែបន្តនិងរីកចម្រើនរហូតដល់ពេលបច្ចុប្បន្ន។ ថ្ងៃបុណ្យប្រពៃណីសំខាន់ៗរបស់ជនជាតិចិនមានដូចខាងក្រោម ៖

### -ទីមួយ ៖ បុណ្យចូលឆ្នាំចិន

កាលពីបុរាណគេហៅបុណ្យចូលឆ្នាំចិនជាបុណ្យ "**យានចិន**" "**យានឃីក**" "**ចឹងតាន់**" ។ល។ អត្ថន័យរបស់វាគឺព្រឹកទី១នៃដើមឆ្នាំ។ ពាក្យថា "**ឆ្លងឆ្នាំ**" ឬចូលឆ្នាំថ្មីគឺជាពិធីបុណ្យចំរុះមួយដ៏អធិកអធមបំផុតរបស់ជនជាតិចិន (សំខាន់បំផុតសំរាប់ជនជាតិហាន់) ។ បុណ្យចូលឆ្នាំមានប្រភពដើមពីបុណ្យ "**ឡាក់ជី**" កាលពីសម័យបុរេប្រវត្តិការចាប់ផ្តើមរបស់បុណ្យនេះគឺជាទូទៅនៅថ្ងៃទី ២៣ ខែ ១២ ចិនហៅថា "**សែនចង្ក្រាន**" រហូតដល់ថ្ងៃទី១៥ ខែ១ ចិនហៅថា "**បុណ្យសែនអ្នកតា**" រយៈពេលនៃបុណ្យនេះមានរយៈពេលយូរហើយ អត្ថន័យនៃបុណ្យក៏មានអត្ថន័យសំបូរបែបលើសលុបជាងបុណ្យដទៃ

ទៀត។ ការឆ្លងបុណ្យចូលឆ្នាំរបស់ជនជាតិចិន រួមមានការហូបបាយឆ្លងឆ្នាំចាស់ជួបជុំគ្នាចាំអាយុលាឆ្នាំចាស់ទទួលឆ្នាំថ្មី ការបិទក្រដាសក្រហម “**ឡូយលាន**” នៅមុខផ្ទះ ការជូនពរគ្នាទៅវិញទៅមក ដុតផាវ ការជូនអំណោយឆ្នាំថ្មីទៅវិញទៅមក។ល។ បុណ្យចូលឆ្នាំថ្មីគឺជាបុណ្យមួយមានលក្ខណៈចំរុះចាប់ផ្ដើមតាំងពីខែ១២ចិន រហូតមកគឺមានសកម្មភាពអបអរដូចខាងក្រោម ៖




ការសំពះចូលឆ្នាំថ្មី



ការកាត់រូបសត្វនិងផ្កាដើម្បីបិទនៅមាត់បង្អួច



ពាក្យស្លោកជូនពរឆ្នាំថ្មីបិទនៅមាត់ទ្វារ



ផាវសុភមង្គល

-**ចាប់ផ្ដើមរៀបចំឥវ៉ាន់ចូលឆ្នាំថ្មីនៅខែ១២ចិន** ៖ តាមប្រពៃណីជនជាតិចិននៅពេលចូលដល់ខែ១២ចិន គឺដល់ពេលសមរម្យសម្រាប់រៀបចំឥវ៉ាន់ចូលឆ្នាំហើយក្រៅពីទិញ គ្រឿងប្រឡាក់ងៀត ដូចជាសាច់ងៀត ត្រីងៀត ស្ពៃជ្រក់... និងស្ករគ្រាប់ជាដើម

ផ្លែឈើស្រស់គឺជាវត្ថុដែលមិនអាចខ្វះបានក្នុងនោះផ្លែប៉ោមគឺតំណាងឱ្យភាពសុខសប្បាយត្រជាក់ត្រជុំ ដូច្នេះទិញច្រើនកាលណាល្អកាលហ្នឹង។

**-ថ្ងៃទី២៤ខែ១២ចិន សែនថ្លែងអំណរគុណទេវតាចង្ក្រាន ៖** តាមរយៈការនិយាយតៗគ្នាមកថាថ្ងៃទី២៤ខែ១២ចិន គឺជាថ្ងៃដែលទេវតាទាំងអស់ត្រឡប់ទៅឋានលើវិញដើម្បីរាយការណ៍ជូនព្រះឥន្ទ្រ ក្នុងនោះទេវតាចង្ក្រានគឺជាទេវតាមួយដែលក្តោបក្តាប់ទៅលើការហូបចុកស្នាក់នៅរបស់ប្រជារាស្ត្រស្ថានកណ្តាលដូចនេះប្រជាជនសុទ្ធតែសែនទេវតាចង្ក្រានដើម្បីបញ្ជាក់ពីអំណរគុណដល់គាត់។ ដង្វាយសម្រាប់សែនទេវតាចង្ក្រានរួមមាន ៖ ផ្លែឈើស្រស់ សាច់ខ្វៃ និងម្ហូបបួស ចំណែកនំអ៊ីនិងស្ករម៉ាយយ៉ាថាំងគឺជាវត្ថុដែលមិនអាចខ្វះបានមានពាក្យចាស់និយាយតៗគ្នាមកថាបង្អែមទាំងនេះអាចបិទមាត់ទេវតាចង្ក្រានបានព្រោះខ្លាចដល់ពេលគាត់ឡើងដល់ស្ថានទេវតារាយការណ៍ផ្តេសផ្តាសទៅព្រះឥន្ទ្រ។ ចំពោះរបៀបនៃការសែនព្រេននោះគឺ ៖ ក្រោយពេលដែលរៀបចំគ្រឿងដង្វាយហើយត្រូវអុជធូបគោរពបូជាក្នុងចិត្តត្រូវបួងសួងសូមឱ្យឆ្នាំក្រោយមានលាភសក្ការៈហូរហៀរ មានសុខភាពល្អមាំមួន រួចហើយអុជក្រដាសសែន ច្រូចស្រា ល្អបំផុតត្រូវយកនំអ៊ីខ្លះទៅចាក់លើចង្ក្រាន រួចហើយយកស្ករម៉ាយយ៉ាថាំងបៀកលាបលើស្លាកទេវតាចង្ក្រាននោះប្រសិទ្ធភាពនឹងកាន់តែល្អទ្វេដង។

**-ថ្ងៃទី២៨ខែ១២ចិន ជាថ្ងៃលាងជម្រះវត្ថុអពមង្គល**

ថ្ងៃទី២៨ខែ១២ចិន គឺជាថ្ងៃល្អសម្រាប់លាងសំអាតវត្ថុប្រើប្រាស់ក្នុងផ្ទះសំបែង បើនិយាយពីប្រពៃណីចិននៅថ្ងៃនេះសមាជិកក្នុងផ្ទះត្រូវរួមដៃគ្នាជួយបោសសំអាតផ្ទះសំបែងគឺបោសសំអាតឧបទ្រពចង្រៃនិងអ្វីដែលមិនល្អ ដែលកើតមានក្នុងឆ្នាំចាស់ឱ្យជ្រះស្រឡះចំណែកបុគ្គលខ្លួនឯងក៏ត្រូវតែសំអាតខ្លួនឱ្យស្អាតរួមទាំងកក់សក់ កាត់សក់ មុជទឹកជម្រះខ្លួនប្រាណឱ្យស្អាត។ល។ តាមការនិយាយតៗគ្នាថាការធ្វើបែបនេះអាចកំចាត់គ្រោះចង្រៃនិងកំចាយជំងឺដង្កាត់ផ្សេងៗ។

**-ជ្រើសរើសថ្ងៃល្អដើម្បីបិទក្រដាសក្រហមមុខផ្ទះ**

នៅរៀងរាល់ឆ្នាំតែងតែមានវេលាល្អមួយសម្រាប់បិទក្រដាសក្រហមនៅមុខផ្ទះ យើងអាចឆែកមើលថ្ងៃល្អបានតាមប្រតិទិន ហើយការបិទក្រដាសក្រហមនេះក៏មានជំណាមខ្លះត្រូវប្រុងប្រយ័ត្នផងដែរ ជាទូទៅប្រជាជននិយមចូលចិត្តយកអក្សរ “**លាភ**” បិទបញ្ច្រាស់

នៅលើទ្វារមានន័យថា “**លាភសក្ការៈមកដល់មុខផ្ទះ**”។ ចំណែកឯការបិទក្រដាសនោះសោតមិនត្រូវបិទ៤សន្លឹកទេ ព្រោះលេខ៤មានសូរដូចនឹងពាក្យស្លាប់មានន័យមិនល្អ។ ល្អបំផុតត្រូវបិទឱ្យគ្រប់៨សន្លឹកតំណាងឱ្យមានតាំងពីសក់ក្បាលរហូតដល់ចុងជើង។ ក្រៅពីនេះត្រូវចាប់អារម្មណ៍ទៅលើពាក្យដែលសរសេរក្នុងក្រដាសក្រហមថាតើមានឆុងជាមួយនឹងឆ្នាំកំណើត របស់សមាជិកក្នុងផ្ទះឬអត់ ឧទាហរណ៍ដូចជាពាក្យថា “**ឡុងម៉ាជីងស៊ីន**” ដែលមានន័យថាស្មារតីល្អដូចជាសេះទេពក្នុងពាក្យមួយឃ្លានេះឆ្នាំ “**រោង**” ឆុងជាមួយឆ្នាំ “**ច**” ចំណែកឯ “**មមី**” ឆុងជាមួយ “**ជូត**” ដូចនេះចំពោះគ្រួសារដែលមានសមាជិកកើតឆ្នាំ “**ច**” និង“**ជូត**” យកល្អមិនគួរបិទពាក្យនេះទេ។



ទេវតាឆ្នាំថ្មី

**-យប់ថ្ងៃទី៣០ខែ ១២ចិន ត្រូវជូនដំណើរឆ្នាំចាស់**

យប់ថ្ងៃទី៣០ ខែ១២ចិន គឺជាថ្ងៃចុងក្រោយបង្អស់នៃឆ្នាំចាស់ ថ្ងៃ១នេះគឺមានអត្ថន័យថាតបស្នងសងគុណនិងការជួបជុំគ្នា។ នៅរសៀលថ្ងៃនោះគឺត្រូវចាប់ផ្ដើមកម្មវិធីជូនដំណើរឆ្នាំចាស់ត្រូវរៀបចំសែនព្រេន១ ដែលមានសំណែន៥មុខ និងជង្ហាយផ្សេងៗដើម្បីថ្វាយទេវតា បន្ទាប់មកទៀតត្រូវសែនកុងម៉ាជីដូនជីតា ដើម្បីថ្លែងអំណរគុណដល់ដូនតានិងទេវតាទាំងអស់ដែលបានថែរក្សាពួកយើងអស់រយៈពេល១ឆ្នាំមកហើយ ថែមទាំងបួងសួងសូមឱ្យពួកគាត់ថែរក្សាពួកយើងបន្តទៀត។ ដល់ពេលយប់សមាជិកក្រុមគ្រួសារជួបជុំគ្នាហូបបាយសាមគ្គី ម្ហូបក្នុងយប់ដាច់ឆ្នាំមានមាន់ ត្រី បន្លែ ហូបយ៉ាងបរិបូរណ៍នេះគឺជាលក្ខណៈពិសេសរបស់វា ជាងនេះទៀតពេលហូបម្ហូបត្រូវហូបតាំងពីដើមរហូតដល់ចប់តំណាងឱ្យភាពគង់វង្សស្ថិតស្ថេរចំណែកម្ហូបត្រីគេមានចេតនាទុកឱ្យសល់ខ្លះតំណាងឱ្យឆ្នាំណាក៏មានបរិបូរណ៍ហូរហៀរសល់នៅដូចឆ្នាំនេះ។ ក្រោយពេលដែលហូបបាយយប់ដាច់ឆ្នាំនេះ ទៅគឺដល់ពេលដែលរៀមច្បងនិងចាស់ៗចែកលុយសង្កត់អាយុដែល

ហៅថា "**អាំងប៉ាវ**" នោះហើយបើធ្វើតាមប្រពៃណីពីបុរាណចិននៅក្នុងកញ្ចប់ក្រហម គឺមានខ្ទប់លុយស្ពាន់១០០កាក់ ដែលគេយកអំបោះក្រហមមកដោតរួចជាស្រេច អត្ថន័យមានន័យថាអាយុវែងដល់រយឆ្នាំ។ ប៉ុន្តែបច្ចុប្បន្ននេះគឺប្រើជាក្រដាសប្រាក់មកជំនួសវិញ ក៏ប៉ុន្តែលុយក្នុងកញ្ចប់ក្រហមត្រូវតែជាលេខគូគឺមានន័យបួងសួងសូមលាភសូមជ័យបានមកទាំងគូរ។ នៅយប់ឆ្លងឆ្នាំមានមនុស្សជាច្រើនមិនចូលគេងទេ គេនៅរង់ចាំយាមអាយុរហូតដល់មេឃភ្លឺបើធ្វើតាមទំនៀមទំលាប់ពីបុរាណ យល់ថាការរង់ចាំអាយុគឺដើម្បីបួងសួងសូមឱ្យឪពុកម្តាយអាយុវែង។ នៅពេលឆ្លងពាក់កណ្តាលអាធ្រាត គឺម៉ោង១២យប់ គឺចាប់ផ្តើមផុតផាវដើម្បីអបអរការមកដល់នៃឆ្នាំថ្មី។

### -ថ្ងៃទី១ ខែ១ចិន សមស្របនឹងសែនដូនតា

ការសែនដូចតានៅថ្ងៃទី១ ខែ១ចិន គឺជាទំនៀមទម្លាប់ដ៏សំខាន់មួយនៅមុខស្លាកព្រលឹងដូនតា គេរៀបចំពុទ្រាក្រហម ស្ករគ្រាប់ ស្ករសណ្តែកដី និងផ្លែឈើស្រស់ ។ល។ បន្ទាប់មកសមាជិកក្នុងផ្ទះអុជធូបគោរពជូនពរគ្នាទៅវិញទៅមក ប្រសិនបើមានមិត្តភក្តិឬញាតិមិត្តមកលេងផ្ទះដើម្បីអបអរឆ្នាំថ្មី ត្រូវមានទឹកមុខញញឹមញញែមស្វាគមន៍ ត្រូវនិយាយពាក្យល្អនៅថ្ងៃទី១នៃថ្ងៃចូលឆ្នាំថ្មីត្រូវតមខឹងច្រឡោតតោតតូង ឬក៏និយាយស្តីពាក្យអពមង្គល។ ក្រៅពីនេះនៅថ្ងៃទី១ មិនត្រូវបោសសំរាមឬចាក់សំរាមចោលឡើយ តាមការនិយាយតៗគ្នាថាការធ្វើបែបនេះនឹងបណ្តេញចេញនូវលាភ សំណាងមិនត្រូវនិយាយពាក្យមិនល្អ បើមិនដូចនេះទេនឹងមានសំណាងអាក្រក់ធ្វើយ៉ាងណាកុំឱ្យមានបែកបាក់កែវចានឬរបស់ប្រើប្រាស់ផ្សេងៗ ប្រសិនបើមិនប្រយ័ត្នធ្វើឱ្យបែកបាក់ត្រូវកែខៃដោយប្រើពាក្យល្អៗមកជំនួស ឧទាហរណ៍ដូចជា ៖ បើបែកចានត្រូវស្រែកថា "**ឆួយឆួអ៊ីងអាន**" មានន័យថាអាយុវែងសុខសប្បាយឬពាក្យថា "**ឡាកទីខាយហ័រ ហ្វកគុយយុងហួរ**" មានន័យថាផ្ការាយពេញដីលាភសក្ការៈមកដល់។ល។



ការរៀបចំសែនដូនតា

**-ថ្ងៃចូលឆ្នាំទី២ ស្ត្រីដែលរៀបការហើយអាចទៅលេងផ្ទះម្ដាយ**

ថ្ងៃចូលឆ្នាំទី២ គឺជាថ្ងៃដែលស្ត្រីដែលរៀបការហើយអាចទៅលេងផ្ទះម្ដាយបាន។ ហេតុអ្វីបានជាថ្ងៃទី១មិនអាចទៅផ្ទះម្ដាយបែរជាទៅនៅថ្ងៃទី២ទៅវិញ? នេះមានការនិយាយតៗគ្នាថាបើសិនជាត្រឡប់ទៅផ្ទះម្ដាយនៅថ្ងៃទី១នឹងធ្វើឱ្យម្ដាយនោះធ្លាក់ខ្លួនក្លាយទៅជាក្រីក្រដូច្នេះហើយទាំងអស់គ្នាត្រូវរង់ចាំដល់ថ្ងៃទី២ទើបត្រឡប់ទៅផ្ទះម្ដាយ។ ក្រៅពីនោះពេលត្រឡប់ទៅលេងម្ដាយ មិនត្រូវទៅដោយដៃទទេឡើយចាំបាច់ត្រូវតែរៀបចំជំនូនខ្លះៗដើម្បីជូនគាត់ដូចជា ស្ករគ្រាប់ ឬក៏ផ្លែឈើស្រស់។ល។

**-ថ្ងៃទី៣ត្រូវតមសម្ដី**

នៅថ្ងៃទី៣ មនុស្សគ្រប់គ្នាត្រូវនៅផ្ទះមិនចេញក្រៅទេ ព្រោះត្រូវតមសម្ដីខ្លាចមានរឿងរ៉ាវដោយសារមាត់។

**-ថ្ងៃទី៤ត្រូវទទួលទេវតាទ្រព្យ**



ទេវតាទ្រព្យ

គេនិយាយថាថ្ងៃទី២៤ខែ១២ចិន ជូនដំណើរទេវតាឡើងឋានលើ ថ្ងៃទី៤ ខែ ១ចិន គឺជាថ្ងៃដែលទេវតាទាំងអស់ត្រលប់ពីឋានលើមកឋានមនុស្សវិញ។ ពាក្យទំនៀមចិនពោលថា “**ជូនទេវតាពីព្រឹក ទទួលទេវតាពីថ្ងៃ**” ដូចនេះពេលជូនទេវតាត្រូវរៀបចំចាប់ផ្ដើមសែនតាំងពីព្រលឹម ចំណែកឯទទួលទេវតាគឺនៅរសៀលថ្ងៃទី៤ ក៏មិនយឺតពេលដែរ។ ចំណែកគ្រឿងជង្វាយរួមមាន ៖ ជង្វាយ៣មុខ (សាច់មាន់ សាច់ជ្រូក និងយីហ៊ឺ) ផ្លែឈើ ស្រា និងម្ហូបថែមទាំងអុជធូប ទៀន និងក្រដាសអាវមាស។ ក្រដាសអាវមាសមាន ៖ សេះទិព្វ សេះដែកនិងសេនាទេព។ល។ សុទ្ធតែត្រូវយកមកសែនដើម្បីទទួលទេវតាទាំងអស់ត្រឡប់មកស្ថានមនុស្សវិញ។

**-ថ្ងៃទី៥ជាថ្ងៃបើកហាងរកស៊ីវិញ**

ថ្ងៃទី៥ កើតតែងហៅថា “**ថ្ងៃកាត់ផ្ដាច់**” នៅថ្ងៃនេះគឺយើងអាចសារគ្រឿងជង្វាយដែលដាក់សែននៅស្លាកទេវតាចេញ។ អ្នកដែលរកស៊ីអាចសំពះទេវតា ដើម្បីបើកហាងរកស៊ីថៅកែចែកអាំប៉ាវឱ្យកម្មករ ដើម្បីសូមបួងសួងសូមជោគជ័យនៅក្នុងមុខរបរទាំងអស់

គ្នា ចំណែកឯតំណមផ្សេងៗដែលមាននៅក្នុងពេលចូលឆ្នាំដូចជាកក់សក់ បោសផ្ទះ ចោលសំរាម។ល។ សុទ្ធតែអាចស្រាយបានហើយទាំងអស់គ្នាអាចត្រឡប់ទៅរកជីវភាពប្រចាំថ្ងៃធម្មតាឡើងវិញ។

**-បុណ្យហែអ្នកតា**

ថ្ងៃទី១៥ ខែ១ចិន ហៅថា "**សាំងយួន**" ឬហៅថា "**យួនស៊ាវ**" ដែលមានឈ្មោះថាហែអ្នកតា។ បុណ្យហែអ្នកតាមានប្រភពមកពីពិធីយកភ្លើងបណ្ដេញបិសាចព្រាយដែលមានតាំងពីបុរាណមកម្ល៉េះ។ លក្ខណៈពិសេសរបស់បុណ្យហែអ្នកតាគឺពេញមួយរាត្រីពោរពេញដោយពន្លឺភ្លើងភ្លឺចិញ្ចែងចិញ្ចាច មនុស្សម្នាអាចគយគន់ទស្សនាពេញមួយយប់ ដូចនេះ បុណ្យនេះគឺត្រូវបានគេហៅថា "**បុណ្យភ្លើង**"។ គ្រប់ទីកន្លែងមានការរៀបចំភ្លើងពណ៌ មានការប្រកួតរចនាភ្លើងពណ៌ មានការប្រកួតប្រជែងទាក់ទងនឹងភ្លើង កូនក្មេងក៏នាំគ្នាយូរចង្កៀងគោមដើរលេងគ្រប់ទីកន្លែង។ ទិដ្ឋភាពដ៏រីករាយបែបនេះបន្តរហូតដល់ថ្ងៃទី១៨ខែ១ចិនទើបបញ្ចប់។ ក្រៅពីនេះនៅថ្ងៃបុណ្យហែអ្នកតាក៏មានការប្រកួតចែវទូកលើគោក រាំនាគ រាំតោ។ល។ ដែលមានលក្ខណៈជាក្រុមៗ។ ការរាំនាគ រាំតោគឺមានធ្វើឡើងដើម្បីជាការរំលឹកគុណដល់ព្រះម៉ែធរណីបួងសួងសុំទឹកភ្លៀងបរិបូរណ៍ រាំនាគគឺដើម្បីបួងសួងសុំឱ្យមានភោគផលបរិបូរណ៍កំចាត់ជំងឺដង្កាត់ចង្រៃ សូមឱ្យមានសុខភាពមាំមួន។



ពិធីយូរចង្កៀងគោម

## -ទីពីរ ៖ បុណ្យឆេងម៉េង

នៅរៀងរាល់ថ្ងៃទី៥ ខែមេសា ខែសុរិយគតិ។ តាំងពីបុរាណចិនបុណ្យ "**ហានសឺជេ**" សែនព្រេនរំលឹកដល់ដូនតាគឺបានក្លាយទៅជាទំនៀមទម្លាប់មួយដែលខានមិនបានទៅហើយ។ ក្រោយរជ្ជកាលថាំង **បុណ្យហានសឺជេ** និង **បុណ្យឆេងម៉េង** ក៏បានធ្វើរួមជាមួយគ្នាជារៀងមកនៅពេលដល់រដូវបុណ្យឆេងម៉េង មនុស្សម្នានាំគ្នាទៅពូនផ្នូរដូនតាដើម្បីសែនព្រេនគឺធ្វើបែបនេះ ដើម្បីសំដែងនូវការនឹកស្រណោះអាឡោះអាឡ័យចំពោះដូចតាដែលបានចែកឋានទៅ។ ចំណែកឯ "**ថាក់ឈីង**" ជាសកម្មភាពមួយផ្នែករបស់បុណ្យឆេងម៉េង មនុស្សម្នាឆ្លៀតឱកាសក្រោយពេលដែលសែនផ្នូរនិងសំអាតផ្នូរដូនតារួចដើរកំសាន្តនៅតាមវាលស្រែឬព្រៃភ្នំ ការធ្វើបែបនេះគេឱ្យឈ្មោះថា "**ឈុនយ៉ូវ**" មានន័យថាការដើរកំសាន្តនៅរដូវផ្ការីកដែលពីបុរាណគេហៅថា "**ថាន់ឈុន**" ឬ "**ស៊ីនឈុន**"។ នៅបុណ្យឆេងម៉េងក៏មានប្រពៃណីដោតស្លឹក "**លីវស៊ុក**" តាមដំណាលតៗគ្នាថាការធ្វើបែបនេះគឺដើម្បីរំលឹកដល់វីរជនត្រកូល "**ស៊ីនណុង**"។

## -ទីបី ៖ បុណ្យសែននំចាំង

បុណ្យសែននំចាំងហៅជាភាសាចិនថា "**ទាន់អ៊ូជា**" គឺជាបុណ្យប្រពៃណីដ៏ធំមួយក្នុងចំណោមបុណ្យប្រពៃណីធំៗរបស់ចិន។ ពាក្យថា "**ទាន់**" មានន័យថាខ្នើតឬកើតដូចនេះហៅបុណ្យនេះថា "**ទាន់អ៊ូ**" មានន័យថា៥កើត ពាក្យថា "**អ៊ូ**" ក្នុងបុណ្យនេះមានសម្លេងដូចនឹងពាក្យថា "**អ៊ូ**" មានន័យថាថ្ងៃត្រង់ហើយបើរាប់តាមថ្ងៃចន្ទគតិចិន ខែ៥របស់ចិនគឺចំពេល "**ខែត្រង់**"។ ហើយដោយសារ "**ខែត្រង់**" នេះចំធាតុឈ្មោលដែលភាសាចិនហៅថា "**យ៉ាងឆិន**" ដូចនេះបុណ្យសែននំចាំងក៏អាចហៅថា "**បុណ្យទាន់យ៉ាង**"។ បុណ្យនេះធ្វើនៅថ្ងៃ៥ ខែ៥ចិនដោយថ្ងៃនិងខែសុទ្ធតែ៥ ដូចនេះក៏មានអ្នកខ្លះហៅបុណ្យនេះថា "**ឆុងអ៊ូ**" មានន័យថា៥ត្រួតគ្នា។ ក្រៅពីនេះបុណ្យសែននំចាំងក៏នៅមានឈ្មោះជាច្រើនទៀតដូចជា "**ស៊ាជា**" "**អ៊ីឡានជា**" "**ឆានចុងជា**" "**ទីឡាក់**" និង "**បុណ្យអ្នកកំណាព្យ**"។ល។ បុណ្យសែននំចាំងមានឈ្មោះផ្សេងៗច្រើនបែបនេះអាចបញ្ជាក់





នំចាំង

ឱ្យយើងមើលឃើញដោយប្រយោលអំពីប្រភពនៃដើមកំណើតបុណ្យនេះ។ ការពិតទៅប្រវត្តិនៃបុណ្យនេះពិតជាមានភាពស្មុគ្រស្មាញរហូតមកដល់ពេលនេះយ៉ាងហោចណាស់ក៏មានរឿងតំណាល៤ទៅ៥រឿងដែលទាក់ទងនឹងបុណ្យនេះ ដូចជារឿងតំណាលដែលទាក់ទងនឹងឈីយាន រឿងតំណាលដែលទាក់ទងនឹងសែនព្រេនរបស់ជនជាតិអ៊ូយាក រឿងតំណាលដែលទាក់ទងនឹងបុណ្យស៊ាជីកដេបីជំនាន់ រឿងដំណាលដែលទាក់ទងនឹងការបណ្តេញថ្ងៃអាក្រក់ខែអាក្រក់។ល។

## -ទីបួន ៖ បុណ្យឈីស៊ីថ្ងៃ៧ខែ៧ចិន

បុណ្យ “**ឈីស៊ី**” មានរឿងដំណាលដ៏ពិរោះមួយ។ រឿងដំណាលនៅក្នុងស្រទាប់ប្រជារាស្ត្របានដំណាលថានៅថ្ងៃទី៧ ខែ៧ចិន តារា២ដួងគឺបុរសគង្វាលគោនិងនារីតម្បាញបានជួបជុំគ្នា។ បើតាមគម្ពីរ “**ឈីស៊ីអ៊ូ**” របស់វ៉ាងប៉ាបានចង្អុលបង្ហាញឱ្យឃើញថាក្នុង១ឆ្នាំមាន៤រដូវ រាត្រីថ្ងៃទី៧ខែ៧ គឺជារាត្រីមួយដែលអាណោចអាធមហើយក៏រាត្រីមួយដែលសាច់ញាតិនិងគូស្នេហ៍បានជួបជុំគ្នា។នៅក្នុងចិត្តរបស់ប្រជាជននារីតម្បាញគឺជាទេពធីតាដែលស្លូតបូត ឧស្សាហ៍ព្យាយាមឈ្លាសវៃនិងមានដៃមួយគូដ៏ប៉ិនប្រសប់ដូចនេះហើយនៅរាត្រីនៃថ្ងៃ៧ខែ៧ចិន ស្ត្រីនិងយុវតីទាំងឡាយសុទ្ធតែចេញមករៀបចំកម្មវិធីសែនព្រេនព្រមទាំងបួងសួងសូមភាពវៃឆ្លាតនិងប៉ិនប្រសប់ពីនារីតម្បាញសង្ឃឹមថាខ្លួនក៏អាចដូចជា

នារីតម្បាញដែរ ដែលមានដៃមួយគូដ៏ប៉ិនប្រសប់និងមានបញ្ញាឈ្លាសវៃអាចទទួលបានសុភមង្គលដ៏ល្អផូរផង់។ ដោយសារ **"បុណ្យឈីស៊ី"** និងស្ត្រីមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយស្ត្រីដូចនេះហើយគេក៏បានហៅបុណ្យនេះថាជា **"បុណ្យស្ត្រី"** នេះគឺជាបុណ្យនារីក្នុងប្រពៃណីចិន។



នារីតម្បាញនិង
បុរសគង្វាលគោ

## -ទីប្រាំ៖ បុណ្យសែនលោកខែ

បុណ្យសែនលោកខែមានទំនាក់ទំនងទៅនឹងរឿង **"ឆាងអឺហោះទៅស្ថានព្រះច័ន្ទ"** ថ្ងៃមួយហូវអ៊ីបានទៅលេងមិត្តភក្តិដែលបួសរៀននៅភ្នំឃុនលុនបានជួបនឹងព្រះម៉ែនិងព្រះឥន្ទ្រដោយចៃដន្យ ហើយក៏បានសូមថ្នាំជីវិតអមតៈ១កញ្ចប់ពីព្រះម៉ែ។ ឮគេនិយាយថាថ្នាំនេះនៅពេលដែលលេបចូលទៅនឹងអាចហោះឡើងទៅលើមេឃក្លាយទៅជាទេវតា។ មិននឹកស្មានថារឿងនេះត្រូវបានភ្ញៀវដែលមកលេងផ្ទះហូវអ៊ី ឈ្មោះផឹងមឹងមើលឃើញ។ ផឹងមឹងរង់ចាំដល់ពេលដែលហូវអ៊ីចេញទៅក្រៅក៏បង្ខំឱ្យឆាងអឺយកថ្នាំជីវិតអមតៈឱ្យខ្លួន ឆាងអឺនៅពេលជួបអាសន្នភ័យពេកមិនដឹងគិតយ៉ាងមេចក៏យកថ្នាំនោះដាក់ចូលក្នុងមាត់រួចលេបបាត់ទៅ។ ក្រោយពេលដែលឆាងអឺលេបថ្នាំនោះរួចខ្លួននាងក៏អណ្តែតឡើងទៅលើមេឃបាត់ដោយសារឆាងអឺនឹកអាល័យប្តីក៏ហោះមកធ្វើជាទេវតានៅថែរក្សាស្ថានព្រះច័ន្ទដែលជាឋានដែលនៅជិតផែនដីជាងគេបំផុត។ ក្រោយពេលហូវអ៊ីត្រឡប់មកវិញអ្នកបំរើក៏រត់មកយំរៀបរាប់ប្រាប់ដំណើររឿងសព្វយ៉ាង។ ហូវអ៊ីឈឺចាប់ខ្លាំងណាស់ងើយទៅ

លើមេឃស្រែកហៅឈ្មោះរបស់ភរិយា ពេលនោះគាត់បានឃើញហេតុការណ៍ដ៏ចម្លែកយប់នោះព្រះច័ន្ទមូលយ៉ាងចម្លែក ភ្លឺច្បាស់យ៉ាងពិសេស ហើយថែមទាំងមានស្រមោលមួយរសាត់មកដូចជារៀងរបស់នាងឆាងអឺ ហូវអ៊ីក៏ប្រញាប់បញ្ជាឱ្យគេរៀបចំតុមួយរួចហើយរៀបចំនំនែកនិងផ្លែឈើដែលឆាងអឺចូលចិត្តញ៉ាំរៀបសែនជូនឆាងអឺដែលនៅក្នុងវិមានច័ន្ទពីចម្ងាយ។ ប្រជារាស្ត្រទូទៅក្រោយស្តាប់ឮនូវរឿងដែលឆាងអឺក្លាយជាទេវតាហោះទៅស្ថានព្រះច័ន្ទ រួចមកក៏នាំគ្នារៀបចំតុដាក់សែននំនែកជូនដល់ឆាងអឺដ៏ស្លូតបូតនេះបួងសួងសូមសេចក្តីសុខសប្បាយ។ ចាប់តាំងពីពេលនោះមកប្រពៃណីបុណ្យសែនលោកខែក៏មានបន្តនៅក្នុងស្រទាប់ប្រជាជនរហូតមក។



ព្រះនាងឆាងអឺហោះ
ទៅស្ថានព្រះច័ន្ទ

## ទំនៀមនៃបុណ្យសែនលោកខែ

ថ្ងៃ១៥ ខែ៨ចិន គឺនៅចំពាក់កណ្តាលនៃរដូវរំហើយ ដូចនេះហើយបានជាគេនាំគ្នាហៅថា "**ចុងឈីវជា**" មានន័យថាបុណ្យពាក់កណ្តាលរដូវរំហើយ ឬបុណ្យសែនលោកខែ។ នៅពេលយប់នៃថ្ងៃបុណ្យប្រជាជននាំគ្នាជួបជុំគ្រួសារគយគន់ព្រះចន្ទជាមួយគ្នាហូបនំលោកខែជាមួយគ្នានេះជាអត្ថន័យដ៏សំខាន់នៃការឆ្លងបុណ្យនេះថែមទាំងយកព្រះច័ន្ទដែលពេញវង់មកធ្វើជាតំណាងឱ្យការជួបជុំគ្នារបស់មនុស្សលោក ដូចនេះក៏មានគេហៅបុណ្យនេះថាជាបុណ្យជួបជុំឬបុណ្យសាមគ្គី។ ប្រពៃណីនៃការគយគន់ព្រះច័ន្ទនៅថ្ងៃបុណ្យមានភាពរុងរឿងនៅសម័យរជ្ជកាលថាំង អ្នកកវីជាច្រើនបានបន្សល់នូវពាក្យកំណាព្យដែលលើកសរសើរពីព្រះច័ន្ទ។ នៅរជ្ជកាលសុង ម៉េង ឆេង។ល។ របៀបនៃការសែនលោកខែទាំងក្នុងរាជវាំងនិងក្នុងស្រទាប់ប្រជារាស្ត្រសុទ្ធមានលក្ខណៈទ្រង់ទ្រាយធំរហូតដល់

បច្ចុប្បន្ននេះនៅមានបន្សល់ទុកនូវប្រាសាទបុរាណជាច្រើននៅគ្រប់ទីកន្លែងនៅក្នុងប្រទេសចិនដូចជាប្រាសាទ **"ប៉ាយយៀកថាន"** **"ប៉ាយយៀកធីង"** **"ស៊ាំងយៀកឡូវ"** ។ល។ ប្រាសាទ **"យៀកថាន"** នៅប៉េកាំងគឺប្រាសាទដែលកសាងឡើងក្នុងរាជស្តេចមីងជាវេឈើងដើម្បីសែនព្រះចន្ទក្នុងរាជវង្សម៉េង។

**-ទីប្រាំមួយ ៖ បុណ្យឆុងយ៉ាង**

នៅថ្ងៃទី៩ ខែ៩ចិន ទាំងខែ ទាំងថ្ងៃគឺសុទ្ធតែលេខ៩ ។ លេខ៩ ត្រួតគ្នាដូចនេះ ទើបហៅថា **បុណ្យឆុងយ៉ាង** ។ បុណ្យឆុងយ៉ាងគឺជាបុណ្យកំសាន្តមួយសកម្មភាពនៃបុណ្យនេះសំខាន់រួមមានឡើងទួលខ្ពស់ គយគន់ផ្កាស្បៃរឿង ផឹកស្រាដែលបិទដោយផ្កាស្បៃរឿង ដោតស្លឹកជូអ៊ីន និងញ៉ាំនំអាកោរក្នុងនោះសកម្មភាពប្រពៃណីដែលលេចធ្លោជាងគេគឺការឡើងទួលខ្ពស់។ ប្រពៃណីនៃការឡើងទួលខ្ពស់ចាប់ផ្តើមតាំងពីរជ្ជកាល **"ស៊ីហាន់"** ក្នុងគម្ពីរ **"ស៊ីជីងថាជិក"** របស់លីវស៊ីន បាននិយាយថា ៖ **"ថ្ងៃទី ៣ខែ៣ និងថ្ងៃទី៩ ខែ៩ ទាំងបុរសទាំងស្ត្រីគឺត្រូវចេញទៅលេងឡើងទីទួលខ្ពស់"** ។ អ្នកនិពន្ធបានយកការត្រួតលេខ ៩ និងត្រួតលេខ ៣ មកប្រៀបធៀបគ្នាហើយថែមទាំងចង្អុល




ផ្កាស្បៃរឿង

បង្ហាញពីអត្ថន័យនៃការឡើងលើខ្ពស់គឺដើម្បីបណ្តេញឧបទ្រពចង្រៃឱ្យចេញពីខ្លួន។ ថ្ងៃទី៩ ខែ៩ បុណ្យឆុងយ៉ាងជាមិនត្រឹមតែឡើងទួលខ្ពស់ជួបជុំគ្នាជប់លៀង ប្រកួតតែងកំណាព្យ ប៉ុណ្ណោះទេវានៅមានសកម្មភាពផ្សេងៗទៀត។ សកម្មភាពទាំងនោះបូកបញ្ចូលទាំង "**ការជួបជុំគ្នាឡើងទីខ្ពស់**" ។ ចំណែកឯ "**ការជួបជុំគ្នាឡើងទីខ្ពស់**"នេះក៏អាចហៅថាជា "**ការជួបជុំជូអ៊ី**" ផងដែរ ដូចនេះហើយគឺបុណ្យនេះក៏ត្រូវវាបានគេហៅថាជា "**បុណ្យជូអ៊ី**" ផងដែរ។

ការផឹកស្រាផ្កាស្បៃរឿងក៏ជាសកម្មភាពដ៏សំខាន់នៃបុណ្យឆុងយ៉ាងនេះផងដែរ។ នៅខែ៩ ផ្កាស្បៃរឿងរីកស្រស់បំព្រងសាយភាយក្លិនយ៉ាងក្រអូបឈ្ងុយឈ្ងប់ ដូចនេះហើយគេក៏ហៅខែ៩ចិនថាជា "**ខែផ្កាស្បៃរឿង**" ។ **ផ្កាស្បៃរឿង** និងបុណ្យឆុងយ៉ាងមិនអាចបំបែកគ្នាបានឡើយ។ បុណ្យឆុងយ៉ាងជាក៏ត្រូវបានគេហៅថា "**បុណ្យស្បៃរឿង**" នៅថ្ងៃនោះ មនុស្សម្នានាំគ្នាគយគន់ផ្កាស្បៃរឿង សៀតផ្កាស្បៃរឿង ផឹកស្រាផ្កាស្បៃរឿង ហូបនំអាកោរក្លិនផ្កាស្បៃរឿង។ល។

## -ទីប្រាំពីរ ៖ បុណ្យសែននំអ៊ី ឬ បុណ្យតុងជឹកជា

ពាក្យថា "**ជឹក**" ក្នុង **បុណ្យតុងជឹកជា** មានន័យថា "**បំផុត**" ។ បុណ្យតុងជឹកជា គឺមានន័យថាជាតុអាកាសត្រជាក់ដល់ទីបំផុត ជាតុឈ្មោលនៃព្រះអាទិត្យចាប់ផ្តើមមានបន្តិចៗ ចំណែកឯរដូវធ្លាក់ទឹកកកផុតទៅ រដូវផ្ការីកក៏ខិតចូលជិតមកដល់ដែរ។ "**រដូវធ្លាក់ទឹកកកជិតផុតទៅហើយ តើរដូវផ្ការីកនៅឆាយទៀតមែនទេ?**" ដូចនេះ **បុណ្យសែននំអ៊ី** គឺជាបារម្ភកថាឬក៏ជាការបើកទំព័ររបស់រដូវផ្ការីក។ នៅថ្ងៃបុណ្យនេះ ពេលថ្ងៃមានរយៈពេលខ្លីបំផុត។ ឆ្លងផុតថ្ងៃបុណ្យនេះទៅពេលថ្ងៃនឹងចាប់ផ្តើមមានរយៈពេលវែងជាងមុនបន្តិចម្តងៗ ថ្ងៃនេះតែងតែជាថ្ងៃដែលគេចុះឬអនុវត្តកិច្ចសន្យា។ មានការនិយាយតៗគ្នាថាកាលពីរជ្ជកាលចូវ គេហៅថ្ងៃមុនថ្ងៃបុណ្យសែននំអ៊ី ១ថ្ងៃថាជាថ្ងៃ "**ស្ងួយជា**" មានន័យថាថ្ងៃចុងក្រោយនៃអាយុ។ រជ្ជកាលបាន់ហៅបុណ្យនេះថាជា "**តុងជា**" មានន័យថាបុណ្យរដូវធ្លាក់ទឹកកក។ ក្រោយរជ្ជកាលសុង មន្ត្រីរាជការត្រូវប្រារព្ធធ្វើពីធីបុណ្យនេះថែមទាំងឈប់សំរាកប៉ុន្មានថ្ងៃទៀតផង ចំណែកប្រជារាស្ត្រត្រូវរៀប

ចំពិធីសែនដូនតា។ល។ ចំណែកអ្នកដែលចេញរកស៊ីនៅខេត្តក្រៅត្រូវរកមធ្យោបាយយ៉ាងណាដើម្បីត្រឡប់មកផ្ទះវិញដើម្បីជួបជុំគ្រួសារ ដើម្បីបញ្ជាក់ថាចុងឆ្នាំអាចត្រឡប់មកផ្ទះ។

## -ទីប្រាំបី ៖ បុណ្យឡាក់ប៉ាជា

នៅថ្ងៃទី៨ ខែ១២ ចិនគឺជាបុណ្យប្រពៃណីជនជាតិចិន ដែលមានឈ្មោះថា "**បុណ្យឡាក់ប៉ាជា**" ឈ្មោះ "**ឡាក់**" គឺជាពិធីសែនព្រេនមួយដែលមានតាំងពីយូរលង់ណាស់មកហើយ ហើយបានកំណត់ជាផ្លូវការនៅរជ្ជកាលហាន់តាំងពីរាជវង្សានុវង្សរហូតដល់ប្រជារាស្ត្រទូទៅសុទ្ធតែត្រូវឆ្លង "**បុណ្យឡាក់ប៉ាជា**" និងចាត់ទុកជាបុណ្យជាតិ។ រហូតដល់ដើមរជ្ជកាលណានឆាវ **បុណ្យឡាក់ប៉ាជា** ត្រូវកំណត់នៅថ្ងៃទី៨ ខែ១២ចិនវិញ។ ប្រពៃណីទំនៀមទម្លាប់នៃបុណ្យនេះគឺ ៖ **ហូបបបរ** ។ មានរឿងតំណាលថានៅថ្ងៃទី៨ ខែ១២ចិន គឺជាថ្ងៃដែលព្រះពុទ្ធបានត្រាស់ដឹងមុននោះដោយសារព្រះពុទ្ធតាំងសីលយូរថ្ងៃពេកមិនបានឆាន់អ្វីសោះក៏ដួលសន្លប់ ក្រោយមកមាននារីគង្វាលចៀមម្នាក់បានប្រគេនបបរមួយចានដល់ព្រះពុទ្ធ ពេលឆាន់រួចទ្រង់បានយកទឹកទន្លេមកទ្រង់ងូតរួចក៏ទៅសមាធិក្រោមដើមពោធិ៍ព្រឹក្សរួចក៏បានត្រាស់ដឹង។ នៅរជ្ជកាលសុងនៅក្នុងវត្តអារាមក៏ដូចជានៅតាមភូមិគ្រប់ផ្ទះនាំគ្នាដាំបបររួចជូសជូនគ្នាទៅវិញទៅមក ទំនៀមទម្លាប់នេះក៏នៅតែបន្តរហូតដល់រជ្ជកាលម៉េង ឆេង។ ថ្ងៃបុណ្យ "**ឡាក់ប៉ាជា**" ក្រៅពីដាំបបរថ្វាយព្រះសែនដូនតាហើយនោះ នៅមានយកបបរមកលាបលើជញ្ជាំង ក្លោងទ្វារ ។ល។ ដើម្បីបញ្ចៀសឧបទ្រពចង្រៃ ឬក៏យកបបរមកលាបលើដើមឈើ ឬផ្កាដើម្បីបណ្ដេញសត្វល្អិតចង្រៃផ្សេងៗទៀតផង ៕

# ជំពូកទី ២

# ទំនៀមទម្លាប់ប្រពៃណី

ទំនៀមទម្លាប់ប្រពៃណី គឺជាបាតុភូតវប្បធម៌មួយដែលមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយ និងវប្បធម៌ការកំសាន្ត ជំនឿសាសនា និងផ្នត់គំនិតរបស់ប្រជារាស្ត្រចិន។ ថ្វីត្បិតតែនេះគឺមានលក្ខណៈបុរាណ គ្រោតគ្រាត ប៉ុន្តែមានលក្ខណៈសាមញ្ញបរិសុទ្ធបង្ហាញពីគោលបំណងដែលប្រជាជនស្វែងរកសុភមង្គលនិងសេចក្តីសុខ ដូចនេះហើយទើបមានកម្លាំងនៃភាពរស់នៅដ៏រឹងមាំនិងយូរអង្វែង។ ក្នុងនោះរួមមាន ៖ ឆ្នាំសត្វទាំង១២ អក្សរសាំងហ៊ីពណ៌ក្រហម ការអុកឡុករាត្រីទឹកឃ្មុំ ការចែកសុតក្រហម ការបង្កក់កូន ការឱ្យលុយតិកអៀ ការជូនពរពេលបុណ្យចំរើនព្រះជន្ម ការបិទអក្សរហុកបញ្ច្រាស ប្រពៃណីនៃការជះកាកថ្នាំ តំណមក្នុងការជាន់ធរណីទ្វារ ការអុជក្រដាសសែន ។ល។

## -ទីមួយ ៖ ឆ្នាំសត្វទាំង១២

មានការនិយាយតៗគ្នាមកថាស្តេចដំបូងគេបំផុតរបស់ចិន ស៊ានយានហ៊ាំងទី ត្រូវការជ្រើសរើសសត្វ១២ មកធ្វើជាអង្គរក្ស។ ឆ្មាបានពឹងពាក់កណ្តុរឱ្យចុះឈ្មោះឱ្យប៉ុន្តែកណ្តុរភ្លេចបាត់ដូច្នេះឆ្នាំសត្វទាំង១២អត់មានឈ្មោះឆ្មាទេហេតុនេះហើយទើបឆ្មានិងកណ្តុរក្លាយទៅជាសត្រូវស៊ីសាច់ហុតឈាមនឹងគ្នា។ សត្វទាំង១២ ក៏ត្រូវបានគេហៅថាឆ្នាំសត្វទាំង១២គឺជាវិធីសាស្ត្រដែលប្រជាជនចិនប្រើសម្រាប់គិតអាយុ។ មនុស្សជំនាន់ដើមគេយកឫកទាំង១២ និងឆ្នាំសត្វទាំង១២មកផ្សំគ្នា ដូច្នេះអ្នកដែលកើតមកនៅក្នុងឆ្នាំមួយណាត្រូវនឹងសត្វមួយណានោះសត្វនោះគឺជាឆ្នាំសត្វរបស់បុគ្គលនោះ។ បាតុភូតនេះកើតមានតាំងពីរជ្ជកាលចូវដែលមានអាយុកាល២.០០០ទៅ៣.០០០ឆ្នាំមុនគ.ស។ មនុស្សម្នាបានយកឆ្នាំសត្វដែលត្រូវនឹងឫកទាំង១២ គឺទទួលឥទ្ធិពលមកពីការគោរពបូជារូបតំណាងសត្វ។ ជំនឿរបស់ប្រជាជនលើឆ្នាំសត្វកំណើតគឺមានឥទ្ធិពលលើជោគវាសនារបស់មនុស្សម្នាក់ៗ ជាពិសេសគឺនៅពេលរៀបការ ។ នៅមានការនិយាយថាមានឆ្នាំឆុងនិងឆ្នាំមិនឆុងជាដើម ។



## -ទីពីរ ៖ អក្សរលាភពណ៌ក្រហមមួយគូ



មានការនិយាយតៗគ្នាថា ៖ វ៉ាងអានសី ចូលរាជធានីដើម្បីចូលរួមប្រឡងមន្ត្រីនៅតាមផ្លូវ គាត់បានឃើញផ្ទះសេដ្ឋីត្រកូលម៉ាចេញប្រធានបទ ដើម្បីរើសកូនប្រសារដែលសរសេរថា **“ឌិះសេះភាន់ភ្លើង ភាន់ភ្លើងឌិះសេះ ភ្លើងរលត់សេះឈប់”** ក្រោយមកវ៉ាងអានសីបានចូលមកដល់ទីលានប្រឡង គណៈមេប្រយោគបានចេញប្រធានបទមួយឃ្លាឱ្យសិស្សប្រឡងតបដែលសរសេរថា ៖ **“ខ្លាហោះភាន់ទង់ ទង់ខ្លាហោះ ទង់រមូលចូលធ្វើឱ្យបាំងខ្លាបាត់”** ។

ក្រោយមក់វាំងអានសឺបានយកប្រធានបទរបស់សេដ្ឋីម៉ាមកតបនឹងប្រធានបទរបស់គណៈមេប្រយោគយកប្រធានបទរបស់គណៈមេប្រយោគតបទៅនឹងប្រធានបទរបស់សេដ្ឋីម៉ា។ ទីបំផុតគាត់មិនត្រឹមតែប្រឡងជាប់ជាមន្ត្រី ហើយថែមទាំងអាចដណ្តឹងអ្នកនាងត្រកូលម៉ាបានថែមទៀត គាត់ត្រេកអរខ្លាំងណាស់ក៏ចាប់ផ្តក់ឡើងសរសេរអក្សរ "**ស៊ី**" ដែលមានន័យថា "**លាភ**" មួយគូជាប់គ្នា។ ចាប់តាំងពីបុរាណរហូតដល់បច្ចុប្បន្នពេលរៀបការមនុស្សម្នាចូលចិត្តបិទអក្សរស៊ីលាភពណ៌ក្រហមមួយគូនៅក្នុងបន្ទប់ផ្សំដំណេក។ គេប្រើក្រដាសពណ៌ក្រហមដើម្បីកាត់ចេញជាអក្សរលាភពណ៌ក្រហម១គូ មានធំមានតូចបិទនៅជញ្ជាំងបន្ទប់ក្រោមពន្លឺទៀនចែងចាំងកាន់តែបន្ថែមនូវភាពរីករាយ និងសេរីមង្គលនៅក្នុងបន្ទប់ផ្សំដំណេកថែមទៀត។ ជាការពិតទៅអក្សរ "**ស៊ី**" មួយគូឬអក្សរ "**លាភ**" មួយគូរនេះមិនមែនជាអក្សរចិនពេញលក្ខណៈទេតែវាជានិមិត្តសញ្ញានៃសិរីមង្គលរបស់ចិនតែប៉ុណ្ណោះ ។

## -ទីបី ៖ ការអុកឡុកបន្ទប់ផ្សំដំណេក

ការអុកឡុកបន្ទប់ផ្សំដំណេកឬហៅម្យ៉ាងទៀតថា "**ការអុកឡុកបន្ទប់ថ្មី**" ជាទូទៅការធ្វើពិធីនេះច្រើនធ្វើឡើងនៅយប់ថ្ងៃរៀបពិធីមង្គលការ ស្ទើរតែអាចរាប់ថាជា "**កម្មវិធីចុងក្រោយបង្អស់**" នៃកម្មវិធីអាពាហ៍ពិពាហ៍ អ្នកចូលរួមក្រៅពីកូនកំលោះ កូនក្រមុំចេញទៅសំខាន់បំផុតគឺយុវជនយុវនារីដែលមានវ័យស្រករនឹងកូនកំលោះកូនក្រមុំ អ្នកចូលរួមបង្កើតកម្មវិធីប្លែកៗផ្សេងៗគ្នាដូចជា ៖ ខាំផ្លែប៉ោម ជូនបារី ទូលប៉េងប៉ោង ។ល។ បង្ខំកូនកំលោះ កូនក្រមុំឱ្យធ្វើជាអ្នកសម្តែងធ្វើយ៉ាងណាឱ្យក្លាយជាបរិយាកាសមួយដែល "**អុកឡុក**" អ៊ូអរនិងសប្បាយ ។

ចំពោះទំនៀមទម្លាប់នៃការអុកឡុកបន្ទប់ផ្សំដំណេកនេះមានប្រភពមកពីចុងសម័យចាន់គ័រ កាលពីរជ្ជកាលថាំងមន្ត្រីរដ្ឋាភិបាលធ្លាប់បានចេញប្រកាសមិនឱ្យប្រកាន់យកទំនៀមទម្លាប់នេះទៀតទេ ប៉ុន្តែក្រោយរជ្ជកាលយួនមកទំនៀមទម្លាប់នៃការ "**អុកឡុកបន្ទប់ផ្សំដំណេក**" នេះក៏បានរុងរឿងឡើងវិញរាប់ពាន់ឆ្នាំហើយមិនកែប្រែ ។

## -ទីបួន ៖ ចែកស៊ុតក្រហម

ចែកស៊ុតមាន់ដែលជ្រលក់ល័ក្ខពណ៌ក្រហមទៅឱ្យសាច់ញាតិ ឬមិត្តភក្តិ គឺជាប្រពៃណីមួយដែលបង្ហាញអំពីទំនៀមទម្លាប់ក្នុងការចូលរួមអបអរឬរីករាយនឹងរឿងល្អអ្វីមួយ។ ជាទូទៅគេច្រើនឃើញធ្វើក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ការសម្រាលកូនឬបង្កក់កូន ។ល។ ជាទូទៅគេយល់ថា **ស៊ុតក្រហម** គឺជាវត្ថុសិរីមង្គលដែលតំណាងឱ្យភាពរុងរឿង។ កាលពីដើមសម័យរជ្ជកាលឈីង មនុស្សម្នាបានប្រើល័ក្ខណចម្រុះពណ៌ដើម្បីមកលាបលើពងមាន់បន្ទាប់មកដាក់ក្នុងទឹកស្ងោឱ្យឆ្អិន រួចយកជូនគ្នាទៅវិញទៅមកនៅពេលចូលឆ្នាំថ្មី។ ប្រហែលជាមកដល់រជ្ជកាលយួននិងម៉េង ទើបទំនៀមនេះកែប្រែក្លាយទៅជាជូនគ្នាតែនៅក្នុងកម្មវិធីមង្គលទៅវិញចំណែកឯពណ៌ល័ក្ខដែលយកមកលាបស៊ុតក៏ជ្រើសរើសយកតែពណ៌ក្រហមមួយពណ៌មកប្រើវិញជាបណ្តើរៗ។



ស៊ុតដែលជ្រលក់
ល័ក្ខពណ៌ក្រហម

## -ទីប្រាំ ៖ ពិធី "ជ័រចូវ"

ពិធី "**ជ័រចូវ**" ដែលមានន័យថា "**ពិធីចាប់យកជោគវាសនា**" ឬខួបកំណើតគំរប់១ឆ្នាំ "**ជ័រចូវ**" ក៏ហៅថា "**ស៊ីកចូវ**" ឬ "**ជ័រលឺ**" ។ល។ គឺជាទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជនចិន។ របៀបនៃការរៀបចំពិធីចាប់យកជោគវាសនាមានលក្ខណៈដូចខាងក្រោម ៖

នៅពេលដែលបុត្រធីតារបស់ខ្លួនមានអាយុគំរប់១ខួប ឪពុកម្ដាយបានយកវត្ថុលេងគ្រប់មុខដូចជា ត្រា សៀវភៅធម៌ ជក់ ក្ដារគិតលេខចិន ប្រាក់កាក់ សៀវភៅគណនី គ្រឿងអលង្ការ ផ្កា ម្សៅ ក្រែម ចំណីអាហារ ។ល។ បើសិនជាកូនស្រីគេត្រូវដាក់ថែមនូវស្ន៊ៀតសក់ វែក គ្រឿងផ្ទះបាយ កន្ត្រៃ ខ្សែម៉ែត្រ អំបោះ (គ្រឿងដេប៉ាក់)។ល។ ដាក់ក្នុងកញ្ច្រែង ដើម្បីឱ្យបុត្រធីតារើសយកតាមចិត្តរបស់ខ្លួន ដើម្បីទស្សទាយពីនិស្ស័យ ចិត្តគំនិតចំណាប់អារម្មណ៍ ឆន្ទៈ និងជោគវាសនារបស់កុមារនោះនៅថ្ងៃអនាគត។ មានការនិយាយតៗ ទំនៀមទម្លាប់នេះមានប្រភពមកពីរឿង "**ស៊ុនឈានស៊ានស៊ឺក**" ។ កាលពីរជ្ជកាលសួយនិងរជ្ជកាលថាងដោយសារប្រទេសចិនមានការបង្រួបបង្រួមទើបទំនៀមទម្លាប់នៃពិធីចាប់យកជោគវាសនាត្រូវបានផ្សព្វផ្សាយមកដល់ភូមិភាគកណ្ដាល ហើយផ្សព្វផ្សាយពាសពេញផ្ទៃប្រទេសចិន។ នៅរជ្ជកាលម៉េងសូម្បីតែមួកមន្ត្រីនិងមកុដិមាសក៏ត្រូវបានគេដាក់ចូលក្នុងកញ្ច្រែងដើម្បីឱ្យទារកទារិការើសផងដែរ ហើយទំនៀមទម្លាប់នេះក៏បន្តមករហូតមកដល់សព្វថ្ងៃ។

## -ទីប្រាំមួយ ៖ លុយសង្កត់អាយុ ឬលុយតិកអៀ

ពាក្យថា "**សួយ**" មានន័យថាអាយុ និងពាក្យថា "**សួយ**" មានន័យថាខ្មោចព្រាយបិសាចនៅក្នុងភាសាចិនគឺមានសូរដូចគ្នាដូចនេះពាក្យថា "**យ៉ាសួយ**" ដែលមានន័យថាសង្កត់អាយុគឺមានសូរសម្លេងដូច "**យ៉ាសួយ**" ដែលមានន័យថាសង្កត់ខ្មោចព្រាយបិសាចដែរ។ នៅយប់ថ្ងៃដាច់ឆ្នាំចាស់ឆ្លងចូលឆ្នាំថ្មីឱ្យលុយតិកអៀទៅក្មេងគោលបំណងគឺដើម្បីសូមសេចក្ដីសុខសប្បាយរំដោះគ្រោះឧបទ្រពចង្រៃ។ ព្រោះប្រជាជនចិន

បុរាណយល់ថានៅយប់ថ្ងៃដាច់ឆ្នាំ ខ្មោចព្រាយបិសាចនឹងមកកាន់ទីលំនៅរបស់ប្រជារាស្ត្រ ដាក់មន្តអាគមកូនក្មេងគឺមានកម្លាំងខ្សោយ ធាតុឈ្មោលតិចងាយនឹងទទួលរងការយាយី ពីខ្មោចព្រាយបិសាចណាស់ដូចនេះត្រូវពឹងលើប្រាក់កាក់ដែលមានធាតុដែកអាចជួយបណ្តេញ ធាតុញីយកឈ្នះលើខ្មោចព្រាយបិសាចបាន និងនាំមកនូវសិរីមង្គល។ បើតាមកំណត់ត្រា ជាលាយលក្ខអក្សរប្រហែលជានៅសម័យរជ្ជកាលចាំងសុទ្ធមានកត់ត្រាថា ៖ នៅពេល ចូលឆ្នាំចិនគឺមានទំនៀមទម្លាប់យកប្រាក់កាក់ធម្មតាមកជាជំនូនជូនពរនៅថ្ងៃចូលឆ្នាំថ្មី។ ចំពោះគ្រួសារកសិករដែលក្រីក្រគ្មានប្រាក់ក៏ប្រើប្រាស់សំបកដើមល្ងមកធ្វើជាវត្ថុសម្រាប់ បណ្តេញខ្មោចព្រាយបីសាចជំនួសវិញ ដោយគិតតាមអាយុរបស់ក្មេងរួចដោតនឹងខ្សែ អំបោះយកពាក់ ឬក៏សៀតក្នុងហោប៉ៅអាវ ប៉ុន្តែគោលបំណងនៃការបណ្តេញខ្មោច ឬ "**សង្កត់ខ្មោច**" នៅតែដដែល។

## -ទីប្រាំពីរ ៖ ជូនពរខួបកំណើត

ការឆ្លងបុណ្យខួបកំណើតរបស់យុវវ័យចិនត្រូវបានកត់ត្រាជាលើកដំបូងបំផុតនៅរជ្ជ កាលចាំងកាលណោះគឺគេចៀនន៌ដើម្បីអបអរបុណ្យកំណើតរហូតមកដល់រជ្ជកាលសុង ទើបមានទំនៀមទម្លាប់ក្នុងការធ្វើពិធីអបអរខួបកំណើត។ ពិធីអបអរខួបកំណើតជាទូទៅ គេប្រារព្ធធ្វើឡើងនៅគំរប់១០ឆ្នាំម្តង ប៉ុន្តែក៏មានតំបន់ខ្លះនិយាយថា "**ធ្វើនៅគំរប់អាយុ ៩ឆ្នាំម្តងគឺមិនធ្វើនៅគំរប់១០ឆ្នាំទេ**"។ នៅថ្ងៃអបអរខួបកំណើតមិត្តភក្តិបងប្អូនសុទ្ធ តែនាំយកអំណោយដើម្បីចូលរួមជូនពរ។ ពិធីអបអរប្រារព្ធធ្វើនៅក្នុងសាលអបអរ ! នៅចំ កណ្តាលសាលមានសរសេរអក្សរ "**សូវ**" ដែលមានន័យថា "**អាយុវែង**" នៅមុខនោះ តំរៀបនូវផ្ទាំងគំនូរដែលជូនពរខួបកំណើត ពាក្យទំនឹបជូនពរក្នុងពិធីខួបកំណើតមាន **ផ្លែ សូដាអាយុវែង** បង្អែមផ្សេងៗ។ អ្នកដែលជាម្ចាស់កម្មវិធីអង្គុយនៅចំកណ្តាលពិធី មិត្តភក្តិនិងសាច់ញាតិត្រូវចូលទៅជូនពរទៅតាមលំដាប់វ័យ។ ក្រោយពេលពិធីជូនពរចប់ សព្វគ្រប់គឺចូលដល់ពិធីសោយភោជនីអាហារ។ មុខម្ហូបមួយមុខចុងក្រោយដែលសំខាន់ បំផុតនោះគឺ "**មីអាយុវែង**" មានន័យថាឱ្យមានអាយុយឺនយូរ។

ផ្លែសេដា



## -ទីប្រាំបី ៖ ការបិទអក្សរលាភបញ្ច្រាស់

ចំពោះទំនៀមទម្លាប់នៃការបិទអក្សរលាភបញ្ច្រាស់នេះមានទាក់ទងនឹងរឿងមួយថា ៖ តាមការនិយាយតៗគ្នាមកថានៅមុនថ្ងៃចូលឆ្នាំចិនមួយថ្ងៃនៅរជ្ជកាលឆេង មេការនៅដំណាក់ព្រះអង្គម្ចាស់កុងម្នាក់ គាត់ធ្វើតាមទំនៀមទម្លាប់សរសេរអក្សរ "**លាភ**" មួយយ៉ាងធំរួចហៅឱ្យអ្នកបំរើយកទៅបិទនៅលើទ្វារធំ អ្នកបំរើនោះមិនចេះអក្សរក៏យកអក្សរ "**លាភ**" មកបិទបញ្ច្រាស់។ មហេសីរបស់ព្រះអង្គម្ចាស់កុងមើលឃើញហើយមានការខឹងសម្បាខ្លាំងណាស់មានបំណងចង់ដាក់ពិន័យដោយវាយនឹងរំពាត់។ មេការមើលឃើញហេតុការណ៍មិនសូវល្អខ្លាចពាក់ព័ន្ធដល់ខ្លួនក៏ប្រញាប់ប្រញាល់លុតជង្គង់ចុះរួចនិយាយថា "ខ្ញុំបាទឮសូរគេនិយាយថាព្រះអង្គម្ចាស់កុងមានទេវតាទ្រព្យសំណាងនៅតាមថៃរក្សាឥឡូវនេះសំណាងធំលាភធំពិតជាមកដល់ហើយដោយពាក្យថា "**បញ្ច្រាស់**" និងពាក្យថា "**មកដល់**" គឺមានសូរសម្លេងដូចគ្នាដូចនេះ "**អក្សរលាភធំបញ្ច្រាស់**" គឺមានសម្លេងដូចនឹងពាក្យថា "**លាភធំមកដល់**"។ ដូចនេះគឺពិតជាប្រថ្នូលដ៏ល្អមួយព្រះអង្គម្ចាស់កុងស្តាប់ឮហើយគិតថាសមហេតុសមផលក្នុងចិត្តគិតថាអញ្ចឹងសោះបានជាអ្នកដំណើរដែលឆ្លងកាត់តាមផ្លូវសុទ្ធតែនិយាយថាដំណាក់ព្រះអង្គម្ចាស់កុងលាភមកដល់ហើយ។ គិតបែបនេះក៏ឱ្យរង្វាន់ដល់មេការនិងអ្នកបំរើម្នាក់៥០តំឡឹង។ ក្រោយមកទៀតទំនៀមទម្លាប់នៃការបិទអក្សរ "**លាភ**" បញ្ច្រាស់នេះក៏បន្តមកដល់ប្រជារាស្ត្រសាមញ្ញទូទៅ។



អក្សរលាភបញ្ច្រាស់

## -ទីប្រាំបួន ៖ ការចាក់កាកថ្នាំ

នៅប្រទេសចិនតែងតែមានអ្នកដែលប្រើប្រាស់មើមថ្នាំចិនដែលស្ងោររួចហើយនោះយកវាទៅរោយឬចាក់នៅលើផ្លូវឬច្រកផ្លូវនានា នេះសរបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ណាស់នូវការបំផ្លាញប្រយោជន៍សាធារណៈនិងការដាក់គ្រោះចង្រៃឱ្យអ្នកដទៃ។ បើតាមការនិយាយតៗគ្នាមកថា ៖ គោលគំនិតរបស់អ្នកដែលធ្វើនោះគឺសង្ឃឹមថាពេលដែលចាក់កាកថ្នាំនៅលើផ្លូវថ្នល់ហើយនោះនឹងមានអ្នកដំណើរដើរជាន់ដោយមិនដឹងខ្លួនពេលនោះនឹងនាំយកនូវជំងឺរបស់ខ្លួនទៅជាមួយដែរ។ ដូច្នេះហើយបើនិយាយបញ្ច្រាសមកវិញជនជាតិចិនគឺមានតំណមមិនត្រូវដើរជាន់លើកម្ទេចកាកថ្នាំដែលគេយកមករោយឬចាក់លើផ្លូវថ្នល់នោះឡើយ។ ហេតុដូចនេះហើយក៏មានទំនៀមទម្លាប់មួយដែលឱ្យឈ្មោះថា “**បោះបង់ជំងឺ១០០មុខ**” ទំនៀមនេះគេច្រើនធ្វើឡើងនៅថ្ងៃទី១ ខែ១ចិន ឬយប់ថ្ងៃដាច់ឆ្នាំស្ត្រីចិននាំគ្នាដើរជាជួរមកដល់ក្បែរស្ពានក៏យកឆ្នាំងដីឬក៏ឧបករណ៍សំរាប់ស្ងោរថ្នាំចិនដែលមានដាក់កាកថ្នាំចិនពេញនោះបោះទៅឆ្នេរខ្សាច់ឬក៏បោះចូលក្នុងទឹកទន្លេទំនៀមនេះគឺធ្វើឡើងដើម្បីបញ្ជាក់ថា “**បើមានជំងឺបណ្តេញជំងឺ បើគ្មានជំងឺគឺការពារជំងឺ**” ។

## -ទីដប់ ៖ តំណាមមិនឱ្យជាន់ខឿនទ្វារឬធរណីទ្វារ

មានពួគេនិយាយតៗគ្នាថាកាលពីយូរលង់ណាស់មកហើយមានគ្រួសារមួយដោយសារខ្ទីលុយគេធ្វើបុណ្យសពឪពុកក៏ក្លាយទៅជាមានបំណុលជាប់ខ្លួន។ ថ្ងៃមួយម្ចាស់បំណុលមកទារបំណុលជើងទាំង២ជាន់លើធរណីទ្វារបន្ទាប់មកអង្គុយនៅលើតៅវាល់អង្ករក្រោយពេលដែលម្ចាស់បំណុលត្រលប់ទៅវិញម្ចាស់ផ្ទះនោះក៏ឈឺរហូតមិនជាសះស្បើយសោះឡើយមានគេនិយាយថា ៖ ធរណីទ្វារគឺជាបំពង់ករបស់មេគ្រួសារនៅពេលដែលគេជាន់ពីលើបែបនេះគឺមិនអាចដកដង្ហើមរួចទេចាប់តាំងពីពេលនោះមកក៏ក្លាយទៅជាច្បាប់ទម្លាប់ ! មានមនុស្សជាច្រើនមានតំណាមមិនឱ្យអ្នកដទៃយកជើងជាន់លើធរណីទ្វារផ្ទះខ្លួនឡើយ។ តាមការពិតទៅច្បាប់ទម្លាប់មួយនេះមានតាំងពីមុនរជ្ជកាលឈីងទៅទៀតនៅក្នុងគម្ពី "**លីជី**" បានកំណត់ថា ៖ "**នៅពេលដែលចេញចូលផ្ទះអ្នកដទៃត្រូវដើរឆ្លងដោយបញ្ចិតខ្លួននៅក្បែរឈើខ្លីដែលគេដោតបញ្ឈរនៅចំកណ្តាលទ្វារផ្ទះ ហើយត្រូវប្រុងប្រយ័ត្នកុំឱ្យជាន់លើធរណីផ្ទះគេអោយសោះ**"។ នៅរជ្ជកាលហាន់មានជំនឿលើទេវតាថែរក្សាទ្វារ ការគោរពបូជាទេវតាថែរក្សាទ្វារគឺប្រែក្លាយពីគោរពនៅតាមវត្តអារាមមកជាការគោរពនៅតាមផ្ទះទៅវិញ។ ដូច្នេះហើយទើបជំរុញឱ្យតំណាមក្នុងការជាន់លើធរណីទ្វារនេះក្លាយទៅជាច្បាប់មួយដ៏តឹងរឹងរបស់ប្រជាជនចិន ។

## -ទីដប់មួយ ៖ ការដុតក្រដាសសែន

មានការនិយាយតៗគ្នាមកថាបងប្រុសរបស់ឆាយលុន ដែលជាអ្នកផលិតក្រដាសមុនគេបំផុតរបស់ប្រទេសចិនឈ្មោះឆាយម៉ក់ គាត់បានរៀនផលិតក្រដាសពីបងប្អូនប្រុសរបស់គាត់រួចបានបង្កើតសិប្បកម្មផលិតក្រដាសដោយខ្លួនឯងដោយសារបច្ចេកទេស គាត់អន់ ដូច្នេះហើយគុណភាពក្រដាសក៏អន់ដែរ ក្រដាសមានលក្ខណៈគគ្រើម មិនរលោងលក់មិនដាច់សោះ។ ដូច្នេះប្រពន្ធគាត់ក៏ធ្វើពុតជាឈឺស្លាប់រួចហើយបង្គាប់ឱ្យឆាយម៉ក់ដុតក្រដាសរួចក៏រស់ឡើងវិញ។ អ្នកដែលឈរមើលជឿថាជាការពិតដូច្នេះហើយក្រដាសដែលសល់

តាំងពីមុនក៏លក់ដាច់អស់មួយរំពេច។ ការដុតក្រដាសសែនគឺជាប្រពៃណីមួយរបស់ប្រជាជនចិនសម្រាប់ពិធីបុណ្យសព ឬសែនព្រេនអ្វីមួយ ។ “**លុយក្រដាស**” កាលពីបុរាណហៅថា “**លុយខ្មោច**” ក្នុងនោះរួមមានលុយកាក់ក្រដាសដែលគេយកក្រដាសពណ៌លឿងឆ្លាក់ចេញជារាងដូចជាប្រាក់កាក់រាងមូលនិងយកទឹកមាសមកលាបពីលើរួចបត់ធ្វើដូចជាដុំមាស ឬក៏យកក្រដាសទៅបោះពុម្ពធ្វើជាលុយខ្មោច។ល។ មានជាច្រើនប្រភេទ។ ចំពោះបរិវេណនៃការប្រើប្រាស់មានបាចតាមផ្លូវនៅពេលហែរសពនៅពេលសែនដោយឬព្យួរនៅលើផ្លូវឬក៏ដុតនៅមុខស្លាកព្រលឹងជាដើម ចំណែកឯការប្រើក្រដាសដុតសែនជំនួសលុយនេះមានកើតឡើងនៅក្រោយសម័យតុងហាន់ដែលឆាយលុនផលិតក្រដាសទៅទៀតប្រពៃណីមួយនេះបានបន្តរហូតមកដល់សព្វថ្ងៃគឺមានរយៈពេលជាងពីរពាន់ឆ្នាំមកហើយ ។



ប្រាក់ក្រដាសសម្រាប់សែន

## -ទីដប់ពីរ ៖ ការរាំនាគ

រាំនាគគឺអច្ឆរិយវត្ថុដែលគេគោរពបូជានៅក្នុងរូបគំនូរតាំងពីបុរាណ។ នៅក្នុងការកត់ត្រាដែលមាននៅក្នុងគម្ពី “**ហាន់ស៊ូ**” បានកត់ត្រាថា ៖ នៅរជ្ជកាលហាន់ នាគដែលរាំមានប្រវែងពី៣០-៤០ម៉ែត្រឡើងទៅគឺមានមនុស្សជាង១០នាក់សម្ដែង។ អ្នកសម្ដែងដែលរាំនាគគឺយកសូត្រព្រៃមកដេរចេញជាខ្លួននាគ ថែមទាំងមានក្បាលនាគនិងកន្ទុយនាគ។ ចំណែកឯការសម្ដែងនោះទៀតសោតគឺដើម្បីកំសាន្តនិងជារបាំម្យ៉ាងផងដែរ។ នៅរជ្ជកាលថាងនិងរជ្ជកាលសុង “**ការរាំនាគ**” ឬ “**ការរាំនាគភ្លើង**” គឺជាការសម្ដែងមួយប្រភេទដែលឧស្សាហ៍ឃើញជាងគេ។

ការរាំនាគ



## -ទីដប់បី ៖ ការរាំតោ

សត្វតោមានប្រភពកំណើតមកពីទ្វីបអាហ្វ្រិកនិងអាមេរិកខាងត្បូងរហូតដល់ក្រោយសម័យរជ្ជកាលហាន់ទើបនាំចូលមកប្រទេសចិន។ ជាទូទៅគេយល់ឃើញថារបាំតោបានកើតមានឡើងនៅសម័យសាមកុកឬនគរ ៣ ដំបូងឡើយវាពេញនិយមនៅតាមជួរកងទ័ពបន្ទាប់មកទើបផ្សព្វផ្សាយពេញក្នុងស្រទាប់ប្រជារាស្ត្រសាមញ្ញហើយក្លាយទៅជាល្បែងកំសាន្តដ៏សាមញ្ញមួយរបស់ប្រជាជនចិន។ នៅរៀងរាល់ពេលចូលឆ្នាំចិនឬក៏ទទួលទេវតាឆ្នាំថ្មីឬក៏កម្មវិធីប្រកួតប្រជែងផ្សេងៗ របាំតោតែងតែបង្ហាញខ្លួននៅតាមស្រុកភូមិនិងទីប្រជុំជននានាបានបន្ថែមនូវបរិយាកាសរីករាយថែមមួយកំរិតទៀត។ នៅសម័យរជ្ជកាលថាងនៅមានរបាំតោ៥ជួបគ្នានៅពេលសម្តែងគឺមានមនុស្សតែងខ្លួនសម្តែងជាតោ៥ ដែលមានពាក់



ក្បាលគោពណ៌ខុសៗគ្នាទាំង៥ នៅពីមុខគោនីមួយៗមានមនុស្ស២នាក់ ពាក់កន្សែងបង់ក ពណ៌ក្រហមដែលមានឈ្មោះថា "**អ្នកដឹកនាំសត្វគោ**" ដើរពីមុខគោនាំផ្លូវគោដោយមានកាន់ផ្តិតញ៉ោះនាំផ្លូវសត្វគោ អ្នកដែលសម្តែងសត្វគោមានក្បាច់និងកាយវិការរាំសព្វបែបយ៉ាង នៅក្បែរនោះមានមនុស្សជាង១០០នាក់ច្រៀងអម ដោយពួកគេច្រៀងបទ ៖ "**សន្តិភាពរីករាយ**" ។ របាំគោដែលជារបាំប្រជាប្រិយជនជាតិចិនមាន២ប្រភេទគឺរបាំគោក្បាច់គុណខាងជើងនិងរបាំគោអក្សរសាស្ត្រខាងត្បូង ។

## -ទីជប់បួន ៖ វត្ថុសិរីមង្គល

ចាប់តាំងពីបុរាណមកប្រជាជនចិនមានចំណាប់អារម្មណ៍និងជំនឿទៅលើវត្ថុសិរីមង្គល និងវត្ថុលាភសំណាងខ្លាំងណាស់។ ចំពោះពាក្យបំប្រួញនៃពាក្យថា "**សិរីមង្គល**" នេះនៅតាំងពីបុរាណបានលេចឡើងហើយពាក្យថា "**ជី**" ដែលមានន័យថាភ័ព្វសំណាងគឺមានទាក់ទងនឹងរឿងផ្នែកលាភសក្ការៈ ចំណែកពាក្យថា "**សុាំង**" ដែលមានន័យថា **ជោគល្អ** ឬ **ប្រផ្នូលល្អ** វាគឺជានិមិត្តរូបនៃការអបអរនិងអ្វីដែលគួរតែអបអរសាទរ។ រាប់ពាន់ឆ្នាំមកហើយវត្ថុសិរីមង្គលរបស់ជនជាតិចិនមានច្រើនណាស់ បរិវេណនៃការប្រើប្រាស់របស់វាមានភាពទូលំទូលាយ ជាក់ស្តែងមិនត្រឹមតែមាននៅក្នុងការហូបចុកស្នាក់នៅ ពិធីមង្គលនានាដូចជា ពិធីរៀបអាពាហ៍ពិពាហ៍ បង្កក់កូនចៅ បុណ្យចម្រើនព្រះជន្មឬបុណ្យកំណើត បុណ្យប្រពៃណីផ្សេងៗ ឬក៏ការកំសាន្តសប្បាយតាមបែបប្រជាប្រិយ។ល។ មិនតែប៉ុណ្ណោះវាថែមទាំងលេចឡើងនៅក្នុងសកម្មភាពនយោបាយ សេដ្ឋកិច្ច សាសនារបស់ចិនជាដើម វត្ថុសិរីមង្គលទាំងអស់នោះរួមមាន ៖ សត្វនាគ ហង្ស សត្វឃីលីងឬសិង្ហទេព ផ្លែសុជាផ្កាមូតាន ជើងប្រាក់ និងថូជាក់ប្រាក់ ទេវតាទ្រព្យ សត្វទន្សាយ ផ្លែទទឹម គង់សេអ៊ីមប្រទានបុត្រ សត្វប្រជៀវ យូអ៊ី បងប្អូនតំបន់ត្រជាក់ទាំង៣ គឺស្រល់ អង្គារសិល្ប៍ និងឬស្សីកុក ប្រើស និងបូចិន។ល។



**ទី១-សត្វនាគ** ៖ រាប់ពាន់ឆ្នាំមកហើយ នៅក្នុងដួងចិត្តរបស់ប្រជាជនចិន សត្វនាគគឺជាទេវតានៃពពកភ្លៀង។ ការគោរពបូជាទៅលើសត្វនាគគឺមានអត្ថន័យជាវប្បធម៌ដូចខាងក្រោម ៖ ១-គេបានចាត់ទុកនាគជារៀមច្បងនៃសត្វល្អទាំងឡាយ ២- គេបានចាត់



សត្វនាគក្នុងចំណោមសត្វទេពទាំងបួន

ទុកនាគជាទេវតាដែលតាមថែរក្សាគេ ៣-គេបានចាត់ទុកនាគជាទេវតាទឹក ៤-មនុស្សបានចាត់ទុកនិងប្រៀបធៀបខ្លួនឯងជានាគ។ បើតាមឯកសារបុរាណបានបញ្ជាក់ថា ៖ ប្រាំមួយពាន់ឆ្នាំមុនមនុស្សនៅលើសម័យវប្បធម៌យ៉ាងសាវ គឺឆ្លងកាត់ការស្នួនរូបសំណាកសត្វនាគនេះបង្ហាញឱ្យឃើញពីគំនិតនៃការចាត់ទុកថា **"សត្វនាគជារៀមច្បងនៃសត្វល្អទាំងឡាយ"** មនុស្សម្នាគោរពបូជាសត្វនាគក្នុងគោលបំណងគឺចង់បានការបញ្ចៀសឧបទ្រពចង្រៃនាំមកនូវសិរីមង្គលនិងសុភមង្គល។ រាប់ពាន់ឆ្នាំមកហើយនៅក្នុងប្រទេសចិនសត្វនាគបានក្លាយនិមិត្តរូបនៃភាពហោះហើរជាទេវដែលមានកម្លាំងអាចសម្រេចកិច្ចការគ្រប់មុខសត្វនាគគឺជាសត្វទេពមួយក្នុងចំណោមសត្វទេពទាំង៤ ដែលមាន ហង្ស ឈីលីង និងអណ្តើក ។

**ទី២-សត្វហង្ស** ៖ តាំងពីបុរាណមកសត្វហង្សគឺជាសត្វទេពសិរីមង្គលដែលស្ថិតនៅក្នុងចិត្តរបស់ប្រជាជនចិន។ ប្រសិនបើស្តេចគ្មានគុណធម៌កាន់កាប់តំណែងធ្វើឱ្យប្រជារាស្ត្រពិបាករស់នៅ សត្វហង្សគឺមិនបង្ហាញខ្លួនឡើយ ។ ពីព្រោះសត្វហង្សគឺមានអត្តចរិតមិនចូលចិត្តនៅលាយឡំជាមួយភាពស្មោគគ្រោកខ្មៅកខ្វក់ឡើយ តែបែរជាចូលចិត្តនៅរាប់

អានជាមួយអ្នកដែលមានចិត្តស្លូតត្រង់ ស្រស់ស្អាត និងយុត្តិធម៌។ គឺមានតែនៅពេលប្រទេសបានសុខសន្តិភាព ស្អាតស្អំ ទើបសត្វហង្សចុះមកឋានមនុស្សលោក។ នៅពេលដែលសត្វហង្សបង្ហាញខ្លួន សត្វបក្សីទេពជាច្រើនក៏បង្ហាញខ្លួនផងដែរដូចពាក្យមួយពោលថា "**បក្សីរយពាន់ទទួលហង្សទេព**" ដូចនេះទើបធ្វើអោយកាន់តែបន្ថែមបរិយាកាសរីករាយមួយកំរិតទៀត ។ មានការនិយាយតៗគ្នាថាកាលពីបុរាណនៅសម័យដែលយ៉ាវ សុន និង អ៊ី និងសម័យដែលចូវកុងកាន់កាប់តំណែងគេធ្លាប់បានឃើញសត្វហង្សបង្ហាញខ្លួននៅស្ថានមនុស្ស។ ចាប់តាំងពីពេលនោះមកប្រជាជនមិនបានឃើញហង្សទេពចុះមកស្ថានមនុស្សដោយផ្ទាល់ភ្នែកទៀតទេ។ មនុស្សលោកបានយកបំណងប្រាថ្នាដែលចង់បានសុភមង្គលពឹងពាក់ទៅលើការគោរពបូជាចំពោះសត្វហង្ស ដូច្នេះហើយទើបសត្វហង្សក្លាយទៅជានិមិត្តរូបនៃភាពរីករាយនិងសុភមង្គល ។



**ទី៣-សត្វឈីលីន** ៖ តើនៅឯណាអាចរកឃើញមុខមាត់ពិតរបស់សត្វឈីលីងនោះ? ការពិតទៅសត្វឈីលីងក៏ដូចជាសត្វនាគនិងសត្វហង្សដែរ គឺសុទ្ធតែជាសត្វដែលកើតឡើងដោយការស្រមើលស្រមៃតាមបែបសិល្បៈរបស់ប្រជាជនចិនហើយរស់នៅក្នុងស្មារតីនិងផ្នត់គំនិតរបស់ប្រជាជនចិនរហូតមក។ សត្វឈីលីងគឺកើតឡើងនៅលើមូលដ្ឋាននៃសត្វប្រើសហើយរួមបញ្ចូលគ្នានូវលក្ខណៈពិសេសរបស់សត្វដទៃទៀត។ នៅក្នុងប្រវត្តិសាស្ត្រមានមនុស្សភាគច្រើនបានហៅសត្វឈីលីងហៅថា "**ឃិនសូវ**" ឬ "**ឃ្វយសូវ**" មានន័យថាសត្វទេព។ សត្វឈីលីងក៏ដូចជាសត្វហង្សដែរ គឺមិនងាយនិងបង្ហាញខ្លួនឡើយ គឺមានតែនៅពេលដែលប្រទេសបានសុខសន្តិភាព ចម្រើនរុងរឿងទើបបង្ហាញខ្លួន។ ដូចនេះហើយទើបអ្នកគ្រប់គ្រងសម័យបុរាណមិនបានយកសត្វឈីលីង



ជានិមិត្តរូបនៃការគ្រប់គ្រងប្រទេសដ៏ឈ្លាសវៃរបស់ពួកគេ។ បើគិតទៅមានតែប្រជារាស្ត្រទើបមានលក្ខណៈរូបិយជាងពីព្រោះពួកគេយល់ថាភាពស័ក្តិសិទ្ធរបស់សត្វឈីលីងគឺការ **"ប្រទានបុត្រធីតា"** ដល់ពួកគេដែលធ្វើឱ្យពួកគេអាចជានាបាននូវពូជពង្សត្រកូលរបស់ពួកគេអាចមានកូនពូនជាចៅ ។

**ទី៤-ផ្លែសេដា** ៖ នៅក្នុងចិត្តរបស់ប្រជាជនចិន ផ្លែសូដាគឺមានពាក់ព័ន្ធនឹងអាយុវែង អារុក្សអារក្ស ទេវតា។ល។ ដូចនេះហើយទើបមានគេហៅថា **"សេដាទេព"** **"សេដាអាយុវែង"** ជាដើមរហូតមកដល់ពេលនេះ មនុស្សម្នានៅតែចាត់ទុកផ្លែសេដាជាវត្ថុសេរីមង្គលដដែលនៅពេលជូនអំណោយខួបកំណើតត្រូវមានផ្លែសូដា ម្ហូប អាហារ បង្អែម នំនែកផ្សេងៗត្រូវធ្វើជារាងផ្លែសេដាដើម្បីផ្តល់ឱ្យមនុស្សម្នានូវការជូនពរដ៏ល្អប្រសើរមួយ។ អ្នកជនបទនៃប្រទេសចិននៅរៀងរាល់ពេលបុណ្យចូលឆ្នាំចិនគេតែងតែបិទរូបផ្លែសេដានៅលើទ្វារ មានតំបន់ខ្លះនៅថ្ងៃចូលឆ្នាំថ្ងៃទី១ ត្រូវតែហូបស៊ុបផ្លែសេដា ពីព្រោះគេយល់ថាផ្លែសេដាគឺមានធាតុមួយក្នុងចំណោមធាតុទាំង៥ គឺ ៖ **"ធាតុទឹក ដី ភ្លើង មាស ឈើ"** ដែលអាចបណ្តេញឧបទ្រពចង្រៃបាន។ ប៉ុន្តែផ្លែសេដាស្រស់មិនមែនមានទាំង៤រដូវទេ ដូច្នេះហើយទើបប្រជារាស្ត្រជ្រើសរើសវិធីចំអិននេះដោយចំអិនជាបីយ៉ាងដែលឱ្យឈ្មោះថា **មីសេដា** ដែលមានស្ទួលរសជាតិគ្រប់បែបយ៉ាងវាបានក្លាយជាអាហារដ៏ពិសេសសម្រាប់រៀបចំពិធីចម្រើនព្រះជន្មឬពិធីខួបកំណើត។ ចំណែកការគូររូបគំនូរផ្លែសេដាជូនជាអំណោយថ្ងៃបុណ្យចម្រើនព្រះជន្មឬបុណ្យខួបកំណើតគឺរិតតែជទង្វើដ៏ល្អមួយដែលមនុស្សជំនាន់ដើមនិយមចូលចិត្ត ។



**ទី៥-ផ្កាមូតាន** ៖ ផ្កាមូតានគឺជាផ្កាមួយប្រភេទដែលអ្នកបុរាណចិនយល់ឃើញថាជាផ្កាដែលល្អនិងស្រស់ស្អាតជាងគេបំផុត ។ អ្នកកវីសម័យរាជកាលថាំងលោក ភីយឹកស៊ីវបានពោលសរសើរផ្កាមូតានក្នុងកំណាព្យគាត់ថា **"បុប្ផាទាំងអស់ដែលរីកសុទ្ធតែចាញ់សម្រស់ផ្កាមូតាន មានតែមូតានទេទើបស្រស់ឆើតឆាយក្រអូបឈ្ងុយ ឈ្ងប់ដែលមានឈ្មោះដ៏ល្អថាជាស្តេចនៃបុប្ផា"** ។ ជាការពិតណាស់ផ្កា

មូតានគឺស្រស់ស្អាតថ្លៃថ្នូរទទួលបាននូវ

ការស្រលាញ់ចូលចិត្តពីប្រជាជនចិនរាប់
ពាន់ឆ្នាំមកហើយ។ នៅរជ្ជកាលថាង
ស្តេចថាង ស៊ានចុង នៅពេលធ្វើបុណ្យ
ចំរើនព្រះជន្មឱ្យស្នំឯក យ៉ាង បានដាក់
បញ្ជាឱ្យគេយកផ្កាមូតានមកពីឡុកយ៉ាង
ប៉ុន្មានដើងមកថ្វាយនៅពេលដែលផ្កា
មូតានរីកពិតជាស្រស់ឆើតឆាយក្លិនក្រអូបឈ្ងុយ ធ្វើឱ្យស្នំឯក យ៉ាង មើលមិនដាក់ភ្នែក ។ ស្តេច ថាំង ស៊ានចុង បានសរសើរផ្កាមូតានថាជាផ្កាល្អលេខមួយ និងបានដាក់រាជបញ្ជាឱ្យសាងសង់សួនផ្កាមូតាន និងដាក់ឈ្មោះឱ្យវាថាជា **ស្តេចនៃបុប្ផា** ។

**ទី៦-ដើមលុយ និងផើងសន្សំទ្រព្យ** ៖ ក្នុងការស្វែងរកភាពមានបាននិងទ្រព្យសម្បត្តិស្តុកស្តម្ភរបស់ជនជាតិចិនជាទូទៅគឺមានទំនាក់ទំនងជាមួយទៅនឹងការប្រមូលភោគផលដំណាំជាមិនខាន ។ ហើយម្យ៉ាងទៀតភាពស្តុកស្តម្ភនេះគឺមានទាក់ទងទៅនឹងមុខ


ទំនិញនៃសេដ្ឋកិច្ចដូច្នេះហើយទើបបានជាបង្កើតឱ្យមាននូវវត្ថុសិរីមង្គលដែលមានលក្ខណៈពិសេសទាក់ទងនឹងមុខទំនិញសេដ្ឋកិច្ចដូចជា ដើមលុយ ផើងសន្សំទ្រព្យជាដើម។ ដើមលុយបើតាមការនិយាយតៗគ្នាមកថាគឺជាដើមសិរីមង្គលម្យ៉ាងដែលអាចនាំលុយកាក់លាភសក្ការៈ មកឱ្យប្រជាជនបានតាមការនិយាយតគ្នាមកថានៅលើដើមលុយនេះ គឺមានមាសកាក់និងមាសស្លឹកនៅព្យួរណោងរណោងពេញដើមនៅពេលដែលយើងរង្គើដើមឬមែកឈើនោះនឹងជ្រុះមាសទាំងនោះចុះមករួចហើយក៏ដុះដុំមាសចេញមកទៀតមិនចេះអស់ឡើយ។ ចំណែកឯផើងសន្សំទ្រព្យវិញក៏ជាវត្ថុសិរីមង្គលម្យ៉ាងដែរកាលពីសម័យបុរាណប្រជាជន ដើម្បីបួងសួងសូមទ្រព្យសម្បត្តិពួកគេពេញនិយមក្នុងការជាវផើងសន្សំទ្រព្យទុកដាក់ក្នុងផ្ទះរៀងៗខ្លួនឬក៏យកក្រដាសក្រហមមកកាត់ចេញរាងជាដើមលុយ ឬ

ផើងសន្សំទ្រព្យ រួចយកមកបិទនៅលើទ្វារឬក៏បង្អួចដើម្បីបួងសួងសូមលាភសក្ការៈ ។

**ទី៧-គង់សីអ៊ីមប្រទានបុត្រ** ៖ ស្ត្រីជនជាតិចិនជំនាន់ដើមគោរពបូជាព្រះនាងគង់សីអ៊ីមក្នុងសាសនាព្រះពុទ្ធជំនឿដ៏ធំបំផុតនោះគឺជឿថាព្រះនាងគង់សីអ៊ីមអាចប្រទានបុត្រ។ គង់សីអ៊ីមមិនមែនជាព្រះដែលមានបុទ្ធានុភាពខ្លាំងលើសគេបំផុតនោះទេ ប៉ុន្តែដោយទ្រង់មានសមត្ថភាពក្នុងការប្រទានបុត្រដូចនេះហើយទើបនៅក្នុងសង្គមចិនគឺគោរពបូជាគង់សីអ៊ីមខ្លាំងណាស់សឹងតែអាចនិយាយបានថាគោរពជាងព្រះពុទ្ធសមគោត្តមទៅទៀត។ វិហារគង់សីអ៊ីម ឬក៏រូបបដិមាគង់សីអ៊ីមគឺមានពាសពេញប្រទេសចិន។ គង់សីអ៊ីមបានផ្សព្វផ្សាយចូលមកប្រទេសចិនតាមរយៈសាសនាព្រះពុទ្ធ ក្រោយពេលដែលគង់សីអ៊ីមចូលមកដល់ប្រទេសចិន វប្បធម៌មានការប៉ះពាល់យ៉ាងខ្លាំង ហើយការប្រែប្រួលខ្លាំងជាងគេនោះគឺការប្រែខ្លួនពីភេទប្រុសមកភេទស្រី **"រូបគំនូរគង់សីអ៊ីមប្រទានបុត្រ"** គឺជារូបគំនូរដែលផ្សព្វផ្សាយមានភាពទូលំទូលាយជាងគេ។ គឺជារូបសិរីមង្គលមួយដែលបួងសួងសូមកូនចៅច្រើន។ គង់សីអ៊ីមគឺជាពោធិសត្វដែលមានមហិទ្ធិឫទ្ធិ គ្មានព្រំដែន គ្មានអ្វីដែលទ្រង់ធ្វើមិនបាននោះទេ។



**ទី៨-សត្វប្រជៀវ** ៖ ជាទូទៅនៅក្នុងចិត្តរបស់មនុស្សយើង សត្វប្រជៀវជាសត្វមិនមានរូបរាងល្អក្នុងក្រសែភ្នែកយើងឡើយស្ទើរតែអាចនិយាយថាជាសត្វដែលមានរូបរាងអាក្រក់ ក៏ប៉ុន្តែហេតុអ្វីបានជាប្រជាជនចិនបែរជាយល់ថាវាជាសត្វសិរីមង្គលទៅវិញ? នោះគឺដោយសារពាក្យថាសត្វប្រជៀវជាភាសាចិនឈ្មោះថា **"ពានហ្វូ"** ហើយអក្សរ **"ហ្វូ"** នេះនិងអក្សរ **"ហ្វូ"** ដែលមានន័យថា **លាភសំណាង** គឺមានសូរដូចគ្នា។ នៅប្រទេសចិនសត្វប្រជៀវអាចចូលផ្សំជាមួយវត្ថុអ្វីផ្សេងដទៃទៀតបង្កើតបានជាវត្ថុសិរីមង្គលបានដូចជាប្រជាជនភាគខាងជើងនៃជនជាតិចិនបានឈូសសរសៃបីមករៀបធ្វើជារាងសត្វប្រជៀវរួចយកសំណ្ដែកក្រហមមកបិទធ្វើជាភ្នែក ចំហុយឱ្យឆ្អិនរួចយកមករៀបដាក់ចានដោយរបៀបផ្សេងៗគ្នាគឺមានអត្ថន័យផ្សេងៗគ្នា។ បើរៀបដាក់ចានពីរទល់មុខគ្នាគេហៅថា

“**ស៊ានហ្វូ**” មានន័យថា **លាភមួយគូ** បើរៀប៥ជារង្វង់គេហៅថា “**អ៊ូហ្វូ**” មានន័យថា **លាភសំណាងទាំង៥** ក្រៅពីនេះបើគេយកសត្វប្រចៀវ ផ្លែប៉េសឬសេដា លុយស្ពូកជាដើមមកដាក់ផ្សំជាមួយគ្នានោះគេហៅថា “**ហ្វូស្វូវស៊ានឈាន**” មានន័យថា “**ទាំងលាភសំណាង ទាំងអាយុវែងមានទាំងព្រម**” នេះជារូបតំនួរសិរីមង្គលមួយរបស់ប្រជាជនចិន ។

**ទី៩-យូអ៊ី** ៖ យូអ៊ីនៅក្នុងប្រវត្តិសាស្ត្រចិន គឺជាអាវុធរបស់មេទ័ពឬមន្ត្រីធំៗ និងគ្រូពេទ្យរាជវាំងប្រើប្រាស់។ ដងរបស់យូអ៊ីធ្វើពីឆ្អឹងសត្វ ឬស្សី គុជ ស្ពាន់។ល។ ដោយគេឆ្លាក់ជារាងបេះដូងអ្នកដែលប្រើប្រាស់វាកាន់វាក្នុងដៃចង្អុលគូសវាសតាមចិត្ត។ យូអ៊ីនៅក្នុងស្រទាប់ប្រជារាស្ត្រទូទៅគេនិយមប្រើប្រាស់សម្រាប់អេះរមាស់។ សម័យឥឡូវនេះប្រវែង



របស់យូអ៊ីបានបង្រួញខ្លីហើយធ្វើអំពីដែក មាស ឈើ គុជស ថ្មកែវ ឬកំឬស្សី។ល។ ដើម្បីសម្រាប់កែកំសាន្ត និងតាំងលំអ។ ដោយសារឈ្មោះរបស់វាល្អមានសិរីមង្គល “**យូអ៊ី**” បានន័យថា “**សំរេចតាមប្រាថ្នា**” ដូចនេះហើយទើបទទួលបានការចាប់អារម្មណ៍និងមើលធ្ងន់ទៅលើវា។ ក្រៅពីនេះគេអាចយក “**យូអ៊ី**” ទៅធ្វើជាអំណោយក្នុងពិធីមង្គលការ ពិធីបុណ្យចំរើនព្រះជន្ម។ យូអ៊ីក៏អាចផ្គុំជាមួយវត្ថុដទៃទៀតបង្កើតបានជាវត្ថុសិរីមង្គលដែរ ឧទាហរណ៍ដូចជាយូអ៊ី១ដាក់នៅចន្លោះផ្លែទន្លាប់២ក្លាយទៅជា “**ស៊ឺកស៊ឺកយូអ៊ី**” មានន័យថា “**រឿងអ្វីក៏សំរេចដូចសេចក្តីប្រាថ្នា**” ជាដើម។ ក្រៅពីតុបតែងនៅពេលបុណ្យទានផ្សេងៗ ប្រជាជនចិនដែលមានជីវភាពធូរធារនិយមចូលចិត្តដាក់តាំង “**យូអ៊ី**” ក្នុងផ្ទះណាស់ ទី១-ជារូបភាពសិរីមង្គល ទី២-ដើម្បីបង្ហាញពីភាពស្តុកស្តម្ភហ៊ឺហារបស់គេ ។

**ទី១០-មិត្តភក្តិតំបន់ត្រជាក់ទាំង៣ ឬស្សី ស្រល់ និងផ្កាអង្គារសិល្ប៍** ៖ ស្រល់ ឬស្សី និងផ្កាអង្គារសិល្ប៍វត្ថុទាំង៣ ផ្គុំគ្នាឱ្យឈ្មោះថា “**មិត្តភក្តិតំបន់ត្រជាក់មានន័យថាមិត្តសំលាញ់ក្នុងតំបន់ត្រជាក់**”។ ពួកគេគឺជាវត្ថុនិមិត្តរូប ឬក៏ជាសាក្ខីភាពនៃស្មារតីមិនចុះចាញ់នូវភាពលំបាកដែលអ្នកករីនិពន្ធចិនតែងតែលើកសរសើរ។ ស្រល់គឺជា “**រៀមច្បងនៃរុក្ខជាតិទាំងឡាយ**” ដើមស្រល់នៅប្រទេសចិនមានច្រើនប្រភេទប្លែកៗគ្នារហូតដល់ជាងម្ភៃប្រភេទហើយថែមទាំងជាឈើដែលមានដើមស្អាត និង




មើលទៅល្អមាំមួនថែមទាំងមានរហ័សនាមថា **អមតៈ** ផងដែរ។ ប្រទេសចិនក៏ជាស្រុកកំណើតរបស់ឬស្សីផងដែរ ឬស្សីនិងប្រទេសចិនគឺមាននិស្ស័យនឹងគ្នាណាស់ សៀវភៅដំបូងបំផុតរបស់ចិនឈ្មោះថា **"រនាបឬស្សី"** គឺគេសរសេរអក្សរនៅលើបន្ទះឬស្សី។ ចំណែកផ្កាអង្គារសិល្ប៍មានច្រើនប្រភេទពណ៌ចំរុះមានភាពធន់និងអាកាសធាតុត្រជាក់ណាស់។ ប្រហែលជាជាង៣.០០០ឆ្នាំមុនជនជាតិចិនបានបន្សាំពូជផ្កាអង្គារសិល្ប៍ព្រៃមកជាពូជផ្កាអង្គាសិល្ប៍ទឹកកក ។

**ទី១១-ក្រុក** ៖ នៅក្នុងវប្បធម៌ចិនបុរាណតែងតែយកសត្វកុកទៅដាក់រួមជាមួយនឹងដើមស្រស់មានគេនិយាយថា **"ក្រុកពាន់ឆ្នាំនៅជាមួយស្រស់ពាន់ឆ្នាំ"** ដូចជាក្នុងកំណត់ត្រារបស់ **"គម្ពីរទេពតា"** បានសរសេរថា ៖ "នៅភាគខាងត្បូងនៃអ៊ីងយ៉ាងឈើនមានរូងថ្ម១នៅក្រោយរូងថ្មមានដើមស្រស់ចាស់១ដើមដែលមានកំពស់រាប់ពាន់ហៀកមានមែកបែកសាខាតែងតែមានសត្វកុក១គូ ហើយហើរមកទុំនៅទីនោះមានកំណត់តៗគ្នាមកថាគ្នានោះមានប្តីប្រពន្ធ១ គូមកទីនេះសំណាក់ធម៌មកស្នាក់នៅនិងតាំងធម៌នៅទីនោះ ចំណែកឯកុកសមួយគូនោះគឺជារូបប្រែក្រឡារបស់



ពួកគេក្រោយពេលដែលពួកគេត្រាស់ដឹងហើយ។ ដូចនេះហើយទើបរូប **"ស្រល់និងក្ងោកអមតៈ"** នេះក្លាយទៅជា រូបភាពសិរីមង្គលរបស់ប្រជាជនចិនរហូតមក។ រូបនេះក្រៅពីជូនពរដល់គូស្វាមីភរិយាដែលមានវ័យចំណាស់អោយមានអាយុវែង ហើយនោះក៏មានបង្កប់អត្ថន័យថាអាចសំរេចធម៌ក្លាយជាទេវតា។

**ទី១២-ប្រើស** ៖ នៅក្នុងជំនឿរបស់ប្រជាជនចិនយល់ឃើញថាសត្វប្រើសជាសត្វសិរីមង្គល។ សត្វប្រើសចូលចិត្តរស់នៅទាំងហ្វូងៗសមត្ថភាពនៃការបង្កកំណើតខ្ពស់ មនុស្សបុរាណយល់ឃើញនិងគោរពបូជាទៅលើការបង្កកំណើត ចំណែកឯសត្វប្រើសគឺតំណាងឱ្យការបង្កកំណើតខ្ពស់។ កាលពីបុរាណគេពេញនិយមក្នុងការជូនស្បែកប្រើស



ធ្វើជាជំនូនក្នុងថ្ងៃមង្គលការនោះគឺជានិមិត្តរូបនៃការបង្កកំណើតមានកូនមានចៅច្រើនបន្តពូជពង្សវង្សត្រកូល។ កម្លាំងនៃការបង្កកំណើតក៏មានអត្ថន័យសំដៅលើកម្លាំងនៃជីវិតរស់នៅ។ ដូចនេះសត្វប្រើសគឺត្រូវបានគេចាត់ទុកថាជាវត្ថុសិរីមង្គលនៃអាយុវែង។ នៅក្នុងសង្គមសម័យបុរាណមានមនុស្សជាច្រើនទទឹងរង់ចាំប្រើសអាយុវែងបង្ហាញខ្លួន។ សត្វប្រើសមិនត្រឹមតែតំណាងឱ្យអាយុវែងប៉ុណ្ណោះទេ ថែមទាំងតំណាងឱ្យភាពស្រឡាញ់និងមេត្តាធម៌ ។ មានការនិយាយតៗគ្នាមកថាប្រសិនបើក្នុងរាជស្តេច អង្គការ ដែលសំបូរហូរហៀរមិនខ្វះអ្វីៗនោះនឹងមានសត្វប្រើសពណ៌បង្ហាញខ្លួនជាក់ជាមិនខាន។ ក្រោយមកដោយសារពាក្យថា **"មន្ត្រី"** ដូច្នេះហើយសត្វប្រើសក៏ត្រូវបានគេយល់ឃើញថាមានន័យជាមន្ត្រីដែលមានឋានៈខ្ពស់រូបភាពសិរីមង្គលនេះក៏ឧស្សាហ៍ឃើញមាននៅក្នុងស្រទាប់ប្រជារាស្ត្រ។

**ទី១៣-ប្ញចិន** ៖ ប្រវត្តិរបស់ប្ញចិនអាចនិយាយបានថាមានប្រវត្តិទាក់ទងនឹងការចងខ្សែរបស់ប្រជាជនចិនតាំងពីរាប់ពាន់ឆ្នាំមុន។ ចំណែកឯប្ញចិនដែលតំណាងឱ្យមនោសញ្ចេតនា ហើយត្រូវបានគេកត់ត្រាមុនដំបូងគេនោះគឺនៅពេលមនុស្សប្រុសរៀបចេញដំណើរមនុស្សស្រីយកក្រណាត់ក្រហមមកចងជាចំណងជំពាក់មុនស្រាយមិនរួចទៅលើ



បង្វិចរបស់គេដើម្បីឱ្យគេឧស្សាហ៍នឹកឃើញគ្រួសាររបស់គេ។ ពាក្យថា “**ជេ**” នៅក្នុងវប្បធម៌ចិនតំណាងឱ្យភាពជិតស្និទ្ធនៃសាច់ញាតិ សាមគ្គីភាព។ អត្ថន័យនៃបូចិនគឺស្ថិតនៅលើរូបរាងនៃការចងចំណងនោះនិងស្ទូរដូចនៃបូនោះ ដើម្បីបញ្ជាក់ពីមនោសញ្ចេតនាបញ្ជាក់ពីអត្ថន័យបានបង្ហាញពីអត្ថន័យដ៏ជ្រាលជ្រៅរបស់ប្រជារាស្ត្រ។ នៅក្នុងប្រវត្តិសាស្ត្រចិន **បូចិន** ឬ “**ចុងគ័រជេ**” ក៏ត្រូវបានគេហៅឈ្មោះថា “**ផាននាងជេ**” នៅរជ្ជកាលថាងគេយកបូចិននោះមកធ្វើជាគ្រឿងសិល្បៈលំអផ្ទះរហូតដល់រជ្ជកាល ឆេង ទើបមានគេដាក់ឈ្មោះឱ្យបូចិនទៅតាមរូបរាងនិងសណ្ឋានរបស់វា។ ចំពោះលក្ខណៈពិសេសរបស់វាគឺបូចិនគឺផ្សំឡើងពីក្រណាត់ឬខ្សែតែមួយសរសៃទេចងតាំងពីលើរហូតក្រោមដោយឆ្លងកាត់ហត្ថកម្មជាច្រើនដូចជាការក្រេង ចង ភ្ជាប់ ព័ទ្ធជុំវិញ រុំ និងត្បាញ។ល។ គឺធ្វើដោយមានរបៀបរៀបរយល្អ ទន្ទឹមនឹងនោះក៏សង្កត់ធ្ងន់លើការតុបតែងឱ្យមានចំនួនស្មើគ្នា ៕

# ជំពូកទី ៣

# ជំនឿផ្សេងៗ

## -ទីមួយ ៖ ហ្វូអ៊ីនិងទីអ៊ែរ

ទេវតាទាំង២គឺជាទេវនៃធាតុញីឈ្មោលជាម្ចាស់នៃមេឃដីនិងវត្ថុទាំងឡាយលើលោក នៅក្នុងគំរូលើផ្ទាំងថ្មរបស់រជ្ជកាលហាន់ ទេវទាំងពីរគឺមានក្បាលមនុស្សខ្លួននាគអាចជារូបដែលលើកព្រះអាទិត្យ ព្រះច័ន្ទ ឬក៏បីព្រះអាទិត្យព្រះច័ន្ទអាចជាដៃកាន់ក្បួនច្បាប់ រីក៏កន្ទុយទាំង២វិញចូលគ្នា។ ដោយសារការផ្សំផ្គុំជាមួយព្រះអាទិត្យព្រះច័ន្ទបង្ហាញឱ្យឃើញពីឋានៈរបស់ហ្វូអ៊ីនិងទីអ៊ែរដែលជាទេវញីឈ្មោលក្នុងការគ្រប់គ្រងផែនដី។ ដៃកាន់ក្បួនច្បាប់គឺតំណាងឱ្យពួកគេមានសិទ្ធិក្នុងការធ្វើឱ្យមានភាពនិងហ្នំនៃមេឃដីរៀបចំឱ្យសណ្តាប់ធ្នាប់មានច្បាប់មានទម្លាប់ត្រឹមត្រូវ។ ចំណែកឯកន្ទុយទាំង២ដេញត្របាញ់ចូលគ្នាគឺបង្ហាញពីការរួមបញ្ចូលគ្នានៃធាតុញីឈ្មោលនិងតួនាទីក្នុងការផ្តល់កំណើតនៃជីវិតថ្មី។ ពួកគេគឺជាអ្នកបង្កើតសង្គមមនុស្ស។ ក្នុងគម្ពី **“ស៊ីឈឺ”** **“គម្ពីស៊ឺអ៊ីជី”** ក្នុងនោះបានលើកឡើងអំពីហ្វូស៊ីបានធ្វើសេម៉ា៨ទិស ចងមងចាប់ត្រី រៀបចំធ្វើពិធីអ្វីមួយកែប្រែលំនៅដ្ឋាន ផ្លាស់ប្តូរការហូបចុកបង្កើតអាវុធពីថ្ម ការបង្កើតគ្រឿងភ្លេង ការបង្កើតអក្សរសាស្ត្រ ឬកិច្ចព្រមព្រៀង ការបែងចែកពេលវេលារដូវ ការរៀបចំទីតាំងតំបន់ បង្កើតក្បួនច្បាប់ក្នុងការរៀបចំការកត់ត្រាតុលាសម្បត្តិ ។ល។



## -ទីពីរ ៖ ព្រះម៉ែស៊ីវ៉ាង

ព្រះម៉ែស៊ីវ៉ាងគឺជាអាទិទេព ដែលទទួលបានការគោរពបូជាបំផុតកាលពីរជ្ជកាលឈើង ហាន់ ។ នៅក្នុងប្រវត្តិសាស្ត្រមានកត់ត្រានិងពិពណ៌នាជាច្រើន។ នៅក្នុងរជ្ជកាលឈាំង ហាន់ គំនូរនៅលើផ្ទាំងសិលាព្រះម៉ែស៊ីវ៉ាងគឺជាអាទិទេពនាំមុខគេដែលមានបារមីខ្លាំងលើគេលើពិភពលោក។ ព្រះម៉ែស៊ីវ៉ាងដំបូងបំផុតលេចឡើងក្នុងពិភពចំលែកពាក់កណ្តាលមនុស្សពាក់កណ្តាលសត្វក្រោយមកប្រែក្លាយជាទេវតាថ្នាំមួយរូបបង្កើតថ្នាំទេពបន្ទាប់មកក៏ប្រែក្រឡាជាទន្សាយគុជ ដែលមានតួនាទីផលិតថ្នាំជីវិតអមតៈក្លាយខ្លួនជាសត្វគីងគក់ ដើម្បីទៅកាន់គ្រឿងផ្សំឬក៏ក្លាយទៅជាបក្សីខៀវដែលសាបព្រោះថ្នាំទេព។ល។ ប្រជាជនដែលរស់នៅក្នុងរជ្ជកាល ឈាំង ហាន់ មានការគោរពបូជានិងជឿជាក់ចំពោះព្រះម៉ែស៊ីវ៉ាងខ្លាំងណាស់សំខាន់បំផុតគឺដើម្បីអាយុវែងអមតៈ ឬក៏អាចសង្គ្រោះមនុស្សពីស្លាប់មករស់រានមានជីវិតវិញ ។

## -ទីបី ៖ អ្នកតាតុងវ៉ាង

អ្នកតាតុងវ៉ាងអាចហៅថាជាអ្នកតាម៉ុក ព្រះបិតា តុងវ៉ាង អាទិទេពហ្វូសាង និងអាទិទេពតុងហ្វ។ ដំបូងឡើយគឺជាអាទិទេពភេទប្រុសរបស់ទេវកថាចិនបុរាណក្រោយមកនៅពេលដែលធម៌តាវចូលមកក្នុងប្រទេសចិនក៏បានតែងតាំងជាអ្នកដឹកនាំទេវតាភេទប្រុសហើយមកដល់រជ្ជកាលណាមសុង និងប៊ីសុង ត្រូវបានប្រសិទ្ធនាមជា **សឺ ជូ** ។

## -ទីបួន ៖ សត្វទេពទាំង៤ ក្នុងរឿងព្រេងចិន

នាគខៀវ ខ្លាស មយ៉ូរាក្រហម សត្វអណ្តើកនិងពស់រួមគ្នាជាទេវតែមួយទាំងនេះគឺជាសត្វទេពទាំង៤ ក្នុងរឿងព្រេងសាសនាតាវ។ សត្វទេពទាំង៤នេះនៅតំណាងឱ្យបក្សីទាំង២៨នៃទិសទាំង៤។ ក្រោយពេលដែលសាសនាតាវល្បីរន្ទឺក្នុងប្រទេសចិនមកសត្វទេពទាំង៤នេះក៏ត្រូវបានដាក់ឈ្មោះមនុស្សផងដែរ ដើម្បីងាយស្រួលក្នុងការហៅដូចជា




សត្វទេពទាំងបួន

នាគខៀវមានឈ្មោះ **មីងចាង** ខ្លាសមានឈ្មោះ **ជៀនពីង** មយ៉ូរាក្រហមមានឈ្មោះ **លីងត័ង** អណ្តើកនិងពស់រួមគ្នាជាទេវមួយមានឈ្មោះថា **ជីម៉ីង**។

**នាគ** គឺជាទេវតាថែរក្សាបក្សីទាំង៧នៅទិសខាងកើត។ នាគនៅក្នុងចិត្តរបស់ប្រជាជនចិនគឺជាទេវដែលអាចហៅភ្លៀងពពកបានយ៉ាងស័ក្តសិទ្ធិ ។

**ខ្លាស** នៅទិសខាងលិច គឺជាសត្វទេពមួយក្នុងចំណោមសត្វទេពទាំង៤របស់ចិន គឺជាសត្វទេពដែលមានមហិទ្ធិរិទ្ធប្រហាក់ប្រហែលនិងនាគខៀវដែរ ខ្លាសគឺជាស្តេចនៃសត្វទាំងអស់មហិទ្ធិឬទ្ធិរបស់វាគឺអាចបង្ក្រាបខ្មោចព្រាយបិសាចបាន ដូចនេះហើយទើបធ្វើឱ្យវាខ្លាចទៅជាសត្វទេពរបស់ **ស៊ូយ៉ាង** តែងតែត្រូវបានគេយកមកនិយាយជាមួយនាគដូចជាពាក្យមួយឃ្លាពោលថា **ពពកគឺនាគហៅមក ខ្យល់គឺខ្លាហៅមក** ។ សត្វខ្លានិងនាគគឺជាដៃគូដ៏ល្អមួយក្នុងការបង្ក្រាបខ្មោចព្រាយបិសាច។ ខ្លាសក៏ជាទេវចម្បាំង និងជាទេវប្រហារផងដែរ។ ខ្លាសនៅមានមហិទ្ធិឫទ្ធិជាច្រើនដូចជាកំចាត់ព្រាយបិសាចបណ្តេញឧបទ្រុព្យចង្រៃបួងសួងសុំភោគផលដំណាំឱ្យបានច្រើននិងជាទេវកំចាត់ភាពអាក្រក់បួងសួងសុំទ្រព្យសុំលាភសក្ការៈនិងជាទេវផ្សំនិស្ស័យគូព្រេងផងដែរ ។

**មយូរ៉ាក្រហម** នៅទិសខាងត្បូងក៏អាចហៅថា **ហាឡុងភ្លើង** ឬ **បក្សីទេព**។ មយូរ៉ាក្រហមគឺជាសត្វទេពមួយក្នុងចំណោមសត្វទេពទាំង៤ សត្វមយូរ៉ាក៏ដូចជាសត្វទេពទាំងបីដទៃទៀតដែរ គឺសុទ្ធតែមានកំណើតពីបក្សីតារាគឺជាបក្សីតារាទិសខាងត្បូង។ ត្បូងទទឹមគឺពណ៌ក្រហមដូចជាភ្លើង ដូចនេះទិសខាងត្បូងគឺចាត់ទុកជាធាតុភ្លើង ដូចនេះទើបមានឈ្មោះថា **ហាឡុងភ្លើង** វានៅមានលក្ខណៈពិសេសមួយគឺអាចរស់រានមានជីវិតឡើងវិញនៅក្នុងគំនរភ្លើងគឺដូចជា **បក្សីអមតៈ** រឺបក្សីមិនចេះស្លាប់របស់ប្រជាជនលោកខាងលិច ដូចនេះហើយទើបមានឈ្មោះថា **ហាឡុងភ្លើង** ។

**ស៊ានអ៊ូ** គឺជាសត្វទេពមួយប្រភេទដែលផ្គុំឡើងពីសត្វអណ្ដើកនិងសត្វពស់ **ស៊ានអ៊ូ** អត្ថន័យរបស់វាគឺ **ស៊ានមីន អ៊ូ** និង **មីន** នៅក្នុងអក្សរចិនបុរាណគឺមានសូរដូចគ្នា ។ **អ៊ូ** មានន័យថាពណ៌ខ្មៅ ឯពាក្យថា **មីន** មានន័យថាស្រទុំ។ ពាក្យថា **ស៊ានមីន** ដំបូងឡើយគឺប្រើដើម្បីពិពណ៌នាអំពីស្នូកអណ្ដើកព្រោះស្នូកអណ្ដើកគឺពណ៌ខ្មៅ ស្នូកអណ្ដើកគឺអញ្ជើញទៅឋានយមរាជ ដើម្បីសួររកដូនតារួចយកចំលើយឡើងមកវិញដោយបង្ហាញឱ្យមនុស្សលោកដឹងជារបៀបប្រស្នាឬក៏ប្រផ្នូល។ ដូចនេះហើយបានជា **ស៊ានអ៊ូ** ពីដំបូងបំផុតគឺជាសត្វអណ្ដើក។ ប៉ុន្តែក្រោយមកអត្ថន័យនៃពាក្យថា **ស៊ានអ៊ូ** បានពង្រីកធំឡើង។ អណ្ដើករស់នៅក្នុងទន្លេ បឹងបួរ និងសមុទ្រ ដូចនេះហើយ **ស៊ានអ៊ូ** បានក្លាយទៅជាទេវតារក្សាដែនទឹក ម្យ៉ាងទៀតអណ្ដើកមានអាយុវែងដូចនេះហើយក៏បានក្លាយជានិមិត្តរូបនៃភាពអមតៈ។ កាលពីដំបូងឡើយ ឋានយមរាជគឺនៅទិខខាងជើងនៅក្នុងឯកសារជ័រគួចាន់នៃរជ្ជកាលអ៊ីនសាងបានសរសេរថា **ឈើប៉ិពិម៉ីសុំាង** បានន័យថាចង់បានជីវិតអមតៈត្រូវធ្វើដំណើរទៅទិសខាងជើងដូចនេះហើយស៊ានអ៊ូក៏បានក្លាយជាទេវតារក្សាទិសខាងជើង។

## -ទីប្រាំ ៖ ទេវតារក្សាទ្វារ

ទេវតាទ្វារ គឺជាទេវថែរក្សាការពារទ្វារផ្ទះដែលសាសនាតាវនិងប្រជាជនមិនគោរពបូជា ប្រជាជនសម័យបុរាណសុទ្ធតែយករូបទេវតាទ្វារមកបិទនៅលើទ្វារដើម្បីបណ្ដេញខ្មោចព្រាយបិសាច និងឧបទ្រពចង្រៃផ្ដល់សេចក្ដីសុខចំរើនដល់គ្រួសារ ថែរក្សាសេចក្ដីសុខក្នុងគ្រួសារ បន្ថែមសិរីសួស្ដីនិងលាភសក្ការៈផ្សេងៗ ថែមទាំងប្រសិទ្ធពរជ័យសិរី

មង្គលដល់ក្រុមគ្រួសារ។ល។ គឺជាទេវតាមួយអង្គក្នុងចំណោមទេវតាដែលទទួលបានការស្វាគមន៍បំផុតពីប្រជារាស្ត្រ។ នៅពេលបុណ្យចូលឆ្នាំថ្មីរឿងដំបូងបំផុតដែលត្រូវធ្វើគឺការបិទរូបទេវតាទ្វារនិងអក្សរក្រហម។ នៅរៀងរាល់ថ្ងៃទី៣០ ខែ១២ចិន (ឬថ្ងៃទី២៩) ប្រជាជនគ្រប់ផ្ទះសុទ្ធតែទៅផ្សារដើម្បីទិញ **ឈុនលាន** (ក្រដាសក្រហមដែលបិទនៅភ្លោងទ្វារពេលចូលឆ្នាំចិន) ប្រសិនបើអ្នកមានកំរិតវប្បធម៌ពួកគេនិងប្រើក្រដាស និងទឹកខ្មៅដើម្បីសរសេរអក្សរដោយខ្លួនឯងហើយ តុបតែងទ្វារក្នុងផ្ទះទាំងក្នុងទាំងក្រៅឱ្យបានស្អាត។ ទេវតារក្សាទ្វាររបស់ជនជាតិចិនសំខាន់ៗមានដូចខាងក្រោម ៖

**ទី១-ទេវតាទ្វារ ដែលចាប់ខ្មោចព្រាយបិសាច ៖ សិនឆា និង អ៊ីឡឺ**

មានរឿងតំណាលតៗគ្នាថាកាលពីបុរាណ សិនឆាននិងអ៊ីឡឺគឺជាបងប្អូន២នាក់មានជំនាញខាងចាប់ខ្មោច ប្រសិនបើមើលមានខ្មោចចង្រៃចេញមកយាយីប្រជាជន សិនឆានិងអ៊ីឡឺនឹងចាប់ពួកគេរួចចង់យកទៅបោះជាចំណីខ្លា។ ក្រោយមកមនុស្សម្នាដើម្បីបណ្ដេញឧបទ្រពចង្រៃ ប្រជាជននិងគូសរូបសិនគារូបអ៊ីឡឺនិងរូបខ្លានៅលើទ្វារអត្ថន័យគឺដើម្បីបណ្ដេញខ្មោចព្រាយបិសាច និងឧបទ្រពចង្រៃ ទំនៀមទម្លាប់នេះបានបន្តរហូតមកដល់សព្វថ្ងៃ។ **ទ្វារខាងឆ្វេងគឺហៅថាសិនគា ទ្វារខាងស្ដាំហៅថាអ៊ីឡឺ ក្នុងប្រពៃណីទំនៀមទម្លាប់មិនហៅពួកគេថាជាទេវតាទ្វារ** ។




ទេវតាទ្វារ សិនឆា និង អ៊ីឡឺ

**-ទេវតាទ្វារ ចុងឃួយ**




ទេវតាទ្វារចុងឃួយ

នៅជ្ជកាលថាំង បានលេចឡើងនូវទេវតាមួយរូបទៀត គឺមានឈ្មោះថា ចុងឃួយ គេមិនត្រឹមតែចាប់ខ្មោចទេថែមទាំងស៊ីខ្មោចទៀតដូចនេះប្រជាជនតែងតែបិទរូប ចុងឃួយនៅលើទ្វារនៅយប់ដាច់ឆ្នាំ ឬក៏ថ្ងៃបុណ្យសែននំចាំងដើម្បីបណ្តេញខ្មោចព្រាយបិសាចឬក៏ឧបទ្រព្យចង្រៃ ។ នៅក្នុងសៀវភៅកំណត់ត្រាទំនៀមទម្លាប់ប្រពៃណីអ្នកស្រុកប៉េកាំងឈ្មោះ **យានជីនសួយសឺជី** របស់ជីងហ្វជីត័រសួយ បានសរសេរថានៅរៀងរាល់បុណ្យចូលឆ្នាំ ឬបុណ្យសែននំចាំងអ្នកក្នុងទីក្រុងតែងតែប្រើក្រដាសពណ៌លឿងកំពស់១ឈៀក (៣៣ចម) បោះត្រាក្រហមពីលើនៅលើក្រដាសនោះអាចគូសរូបទេវតាទ្វារចុងមួយឬគូសរូបយ៉ាន់ពិស៥ ដាក់ព្យួរលក់គឺសុទ្ធតែត្រូវបានប្រជាជនដណ្តើមគ្នាទិញយកទៅបិទនៅលើទ្វារដើម្បីបណ្តេញឧបទ្រពចង្រៃ។ ចំណែកឯរូបនោះវិញ គឺមានក្បាលខ្លារខិន ពុក មាត់នាគ ភ្នែកមូលដូចកាក់ ច្រមុះដូចទំពក់ ត្រចៀកដូចផ្លង នៅលើក្បាលមានពាក់អ្នកអ៊ូសាគឺមួកដែលធ្វើឡើងពីស្បែពណ៌ខ្មៅ ពាក់ស្បែកជើងពណ៌ខ្មៅ ស្លៀកសំលៀក បំពាក់ពណ៌ក្រហម ដៃស្តាំកាន់ដាវ ដៃឆ្វេងចាប់ខ្មោច បើកភ្នែកធំៗសំឡក់មើលទៅពិតជាមានអំណាចនិងកាចសាហាវខ្លាំងណាស់។ ឮគេល្បីតៗគ្នាមកថាសមត្ថភាពចាប់ខ្មោចរបស់គាត់គឺខ្ពស់ជាងសិនឆា និងអ៊ីុឡឺខ្លាំងណាស់ ។

**ទី២-ទេវតាទ្វារជាមេទ័ពមានឈ្មោះ ឈីនស្យុង អ៊ួយឆឺកុង អ៊ុន ស្យុងយៀកហ្វឺ**

ដោយសារការវិវត្តនៃសម័យកាល ជំនឿរបស់ប្រជាជនចិនក៏ចាប់ផ្តើមមានការកែប្រែទៅជាផ្លូវលោកដែរ។ ជំនឿទៅលើទេវតាទ្វារក៏មានការកែប្រែដ៏សំខាន់មួយគួរឱ្យកត់សំគាល់ផងដែរ ក្រោយសម័យរជ្ជកាលយាន រជ្ជកាល ម៉េងទៅប្រជាជនមួយចំនួននៅតែ



ទេវតាឈើងស្យុង



ទេវតាអ៊ួយឆឺកុង

មានជំនឿលើទេវតាទ្វារដែលជាការជឿជាក់តាំងពីបុរាណមកមានខ្លះទៀតគឺមានការកែប្រែដោយមានជំនឿទៅលើទេវតាទ្វារដែលមានការកែប្រែថ្មីដោយបានចាត់ទុកមេទ័ពដែលមានថ្វីដៃខាងចម្បាំងខ្លាំងពូកែមកគោរពបូជាធ្វើជាទេវតាមានមហិទ្ធិឫទ្ធិអស្ចារ្យក៏បានដាក់រហស្សនាមថាជាទេវតាទ្វារជាមេទ័ពដោយបានកំណត់យក **ឈើងស្យុង អ៊ួយឆឺកុង ថិនស្យុង យៀកហ្វី** ។ល។

**-ទេវតាទ្វារបួងសួងសូមលាភ**

ទេវតាទ្វារបែបនេះមិនមែនជាទេវថែរក្សាទ្វារនោះទេ គឺជាទេវតាសំរាប់បួងសួងសូមលាភសក្ការៈប៉ុណ្ណោះ ទេវតានោះគឺមានទេវតាប្រទានទ្រព្យនិងលាភសក្ការៈ **ឈីកហ្វូឆានគាន់** ក៏មានទេវតា **លីវហាយស៊ីជីនចាន** ដែលជាទេវទ្រព្យតូចដែលហៅទ្រព្យជាដើម។ អ្នកដែលគោរពបូជានិងបិទរូបទេវតាទ្វារបួងសួងសូមលាភនេះភាគច្រើនគឺជាអ្នកប្រកបរបររកស៊ីជួញដូរ ពួកគេសង្ឃឹមថានឹងអាចទទួលបាននូវលាភសក្ការៈបុណ្យស័ក្តិប្រាក់កាក់ទ្រព្យធននានាពី **ទេវតារក្សាទ្វារ** ។

**-ទេវតាទ្វារក្នុងសាសនាតាវ**

ភាគច្រើនមិនបិទនៅក្នុងទ្វារផ្ទះរបស់ប្រជាជនសាមញ្ញទេ ប៉ុន្តែច្រើនបិទនៅតាមផ្លូវទ្វារក្រុងនៅក្លោងទ្វារភ្នំមានទេវតាពីរអង្គ **ខាងឆ្វេងគឺទេវតានាគខៀវ មឹងចាង ខាងស្តាំ គឺទេវតា ខ្លាស ជៀន ពីន** ។

## -ទីប្រាំមួយ ៖ ទេវតាទ្រព្យ

ទេវតាទ្រព្យ គឺជាទេវតាមួយអង្គក្នុងសាសនាតាវគឺជាទេវតាមួយអង្គដែលប្រជាជនចិនគោរពបូជាបួងសួងសូមទ្រព្យសម្បត្តិសូមលាភសក្ការៈ។ ប្រជាជនតែងតែប្រាថ្នាចង់បាននូវជីវភាពដែលសម្បូរសុក្កសុម្ភនិងសុភមង្គល ហើយការដែលស្វែងរកនូវជីវភាពដ៏ល្អរបស់ប្រជាជនជាទូទៅគឺមានពាក់ព័ន្ធជាមួយនឹងការស្វែងរកទ្រព្យសម្បត្តិបានច្រើនឬតិច។ ដូចនេះហើយទើបមានមនុស្សជាច្រើនមានការគោរពបូជាចំពោះទេវតាទ្រព្យសង្ឃឹមថាទេវតាទ្រព្យអាចប្រទានទ្រព្យ ។ ទេវតាទ្រព្យគឺជាទេវតាមួយអង្គដ៏ស័ក្តិសិទ្ធដែលប្រជាជនក្នុងសម័យបច្ចុប្បន្នប្រាថ្នាចង់ជួប។ ទេវតាទ្រព្យកើតមានឡើងក្នុងរជ្ជកាលសុងក្រោយមកមានការពេញនិយមកាន់តែខ្លាំងឡើងៗ ហើយមានមូលដ្ឋានគ្រឹះយ៉ាងទូលំទូលាយក្នុងស្រទាប់ប្រជារាស្ត្រទូទៅ។ នៅក្នុងប្រវត្តិសាស្ត្រមានទេវតាទ្រព្យជាច្រើនទេវតាទ្រព្យដែលឧស្សាហ៍ជួបជាងគេមានដូចខាងក្រោមនេះទេវតាទ្រព្យអក្សរសាស្ត្រ **ពីកាន** និង**ហ្វាន់លិ** ។

**-ពីកាន** ៖ ទេវតាទ្រព្យដែលមានគូរក្នុងគំនូររបស់ប្រជារាស្ត្រទូទៅភាគច្រើនគឺជារូបរបស់ពីកានមានការស្លៀកពាក់តុបតែងជាមន្ត្រីអក្សរសាស្ត្រ ពាក់មួយមន្ត្រី មានពុកមាត់វែង នៅក្នុងដៃមានកាន់យូអ៊ី ស្លៀកពាក់អាវជាយមន្ត្រីរូបពស់ថ្លាន់ ជើងជាន់មាសស្លូកមុខមាត់រាងស្គមនិងស្អាតបាត ទឹកមុខមាំ ក្នុងកំនត់ត្រាទី៣នៃ **គម្ពីរអ៊ីហ្វិនជី** នៃ **គម្ពីរស៊ីជី** របស់ស៊ីម៉ាឈានបានកត់ត្រាថាស្ដេចសាងចូវវ៉ាងស្រឡាញ់និងជឿសំដីរបស់ស្នំឯកតាជីខ្លាំងណាស់ទ្រង់ក្លាយទៅជាស្តេច អាក្រក់មិនគិតគូពីប្រជារាស្ត្រ គិតតែពីសម្រស់ស្រីស្អាតមិនគិតគូពីការងាររាជការថែមទាំងបន្ថែមពន្ធអាកររឹបអូសទ្រព្យសម្បត្តិប្រជារាស្ត្រ មន្ត្រីធំដែលស្មោះត្រង់ឈ្មោះ អួយ ជឺ បានផ្ញើលិខិតនិងគំនិតផ្ដល់ការណែនាំជាច្រើនដងដល់ទ្រង់ ប៉ុន្តែមិនទទួលបានលទ្ធផលទាល់តែសោះទាល់តំរិះក៏ចាកចេញដោយខ្លួនឯងទៅ។ ចំណែកឯ ពីកាន គឺជាម្ចាស់មារបស់ស្ដេច សាង ចូវវ៉ាង ទ្រង់មានចិត្តស្មោះត្រង់ចំពោះរាជការនិងព្រះមហាក្សត្រតែងតែចូលគាល់និងទូលនូវសំដីពិតជាច្រើនដល់ស្តេចសាងចូវ"វ៉ាងព្រោះគាត់យល់ថាក្នុងនាមជាមន្ត្រីម្នាក់បើស្តេចមានកំហុសមិនត្រូវមើលបំណាំនោះទេត្រូវជួយកែលំអឡើងវិញ ដូច្នេះហើយក៏ចូលគាល់ទ្រង់រង់ចាំអស់រយៈពេល៣យប់៣ថ្ងៃមិនត្រឡប់មកផ្ទះ ស្តេចសាងចូវវ៉ាងខ្ញាល់ជាខ្លាំងហើយថែមទាំងបានស្ដាប់សំដីអុចអាលរបស់

តាជីថៃមទៀតនោះបានដាក់បញ្ជាឱ្យអាមាត្រចាប់ ពីកាន យកទៅវះបេះដូងចេញមកក្រៅ។ បើតាមការនិយាយតៗគ្នាមកថាប្រជាជនដែលរកស៊ីដែលនៅក្រោមការគ្រប់គ្រងថែរក្សារបស់ពីកានទាំងអស់សុទ្ធតែជាមនុស្សស្មោះត្រង់មិនចេះប្រើល្បិចដាក់គ្នាពួកគេរកស៊ីដោយយុត្តិធម៌ អ្នកណាក៏មិនចេះរកស៊ីបោកប្រាស់ឬមានល្បិចកលអ្វីឡើយ។ មានពាក្យសុភាសិតមួយពោលថា៖ **គ្មានឈ្មួញណាដែលគ្មានល្បិច បើគ្មានល្បិចគឺមិនមែនជាឈ្មួញ** ប្រជារាស្ត្របានយកពាក្យថា **គ្មានចិត្ត** មកកំណត់ពាក្យថា **យុត្តិធម៌** មកបង្ហាញពីទឹកចិត្តរបស់ប្រជាជនក្នុងការស្អប់ខ្ពើមអ្នកដែលប្រើល្បិចកិចកលក្នុងទំនាក់ទំនងរកស៊ី និងការប្រាថ្នាចង់បាននូវសង្គមមួយដែលមានភាពស្មោះត្រង់ជឿជាក់ ។

**-ហ្វាន់លិ** ៖ គឺជាមន្ត្រីដែលមានឈ្មោះល្បីក្នុងប្រទេសយៀកក្នុងចុងរជ្ជកាលឈុនឈីវ។ គាត់បានជួយជ្រោមជ្រែងកូវជៀនឱ្យវាយឈ្នះហ្វូឆាយរបស់ប្រទេសអ៊ូ។ ក្រោយពេលដែលកូវជៀនបានក្លាយជាស្តេច ក៏បានប្រទានតំណែងឱ្យហ្វាន់លិធ្វើជាសេនាប្រមុខក្រោយពេលគាត់បានទទួលដំណែងរួចគាត់ជាមនុស្សវាងវៃចេះយល់សភាពការណ៍មិនចង់ធ្វើការងាររាជការទេក៏នាំក្រុមគ្រួសារជិះទូកតាមសមុទ្ររហូតមកដល់ប្រទេសឈីហើយបានកែឈ្មោះប្តូរត្រកូលនិងប្រកបរបរជាឈ្មួញ ហ្វាន់លិ ពូកែខាងជំនួញណាស់គាត់ធ្លាប់បានរកស៊ីហើយចំណេញប្រាក់ជាច្រើនចំនួន៣លើក ហើយបានដាក់ទានទៅឱ្យជនក្រីក្រនិងសាច់ញាតិសណ្តានក្រោយមកគាត់ធ្វើជំនួញកាន់តែធំ និងក្លាយទៅជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ។ អ្នកជំនួញទាំងអស់សុទ្ធតែគោរពស្ងើចសរសើរគាត់គ្រប់ៗគ្នា ។

**-ទេវតាទ្រព្យក្បាច់គុណ ចាវកុងមីង និង តាន់អ៊ី**



ចាវកុងមីងមានត្រកូលចាវ ឈ្មោះឡាង រហស្សនាមកុងមីង ប្រជាជនតែងហៅថាជាសេនាប្រមុខចាវកុងយានចំណែកឯមុខមាត់របស់គាត់គឺមុខខ្មៅ ចិញ្ចើមក្រាស់ ពាក់មួកដែក ដៃកាន់រំពាត់ដែក ជើងម្ខាងជាន់ខ្លាខ្មៅ ដូចនេះហើយទើបមានរហស្សនាមថាជាទេវខ្លាខ្មៅ។ ចាវកុងមីងគឺជាទេវថែរក្សាឋានសួគ៌មួយរូបដែលសាសនាតាវបានគោរពបូជា។ ថ្វីត្បិតតែចាវកុងមីងមានឋានៈតូចតាចនៅក្នុងសាសនា ប៉ុន្តែនៅក្នុងស្រទាប់ប្រជារាស្ត្រទូទៅគឺមានការពេញនិយមខ្លាំងណាស់។ ជាំងជីយ៉ា ក្រោយ

ពេលទទួលការប្រទានឱ្យធ្វើជាយានសីធានជន់រួចមកបានប្រទានងារឱ្យចាវកុងមឹង ជា **នាគមាសយូអ៊ីចឹងនៃទេវខ្លានាគ** បានដឹកនាំសេនាទេវតាបួនរូបគឺទេវស្វែងរកទ្រព្យស៊ាវសឹង ទេវរក្សាវត្ថុមានតំលៃឆាវប៉ាវ ទេវស្វែងរកលាភឈិនជីវកុង និងទេវរក្សាប្រយោជន៍ចាវសាវស៊ិកការងាររបស់ពួកគេគឺ ៖ **ប្រទានលាភសំណាងនិងសុភមង្គល កំចាត់ឧបទ្រពចង្រៃជូនប្រជារាស្ត្រ** ។ ក្រោយរជ្ជកាលម៉េង ប្រជាជនចិនដែលគោរពបូជាទេវតាទ្រព្យចាវកុងមឹងកាន់តែមានចំនួនច្រើនឡើងៗពួកគេបួងសួងសូមទ្រព្យសូមលាភ ។

-ទេវតាទ្រព្យ គាន់ អ៊ី

គឺជាទេវតាទ្រព្យមួយអង្គទៀតដែលចេះក្បាច់គុណ។ គាន់អ៊ីមានរហស្សនាមអ៊ីនឆាងពីដំបូងឡើយជាសេនាប្រមុខក្នុងរជ្ជកាលចុងក្រោយនៃសម័យតុងហាន់ជាវីរបុរសសច្ចធម៌ គឺជាវីរបុរសដែលប្រជាជនគ្រប់គ្នាយល់ថាជាមនុស្សមានគុណធម៌ត្រូវបានតែងតាំងជាមន្ត្រី ថ្នាក់ទី៧តាំងពីនៅវ័យក្មេង។ រជ្ជកាល ម៉េងឆេង កេរ្តិ៍ឈ្មោះរបស់គាន់អ៊ីកាន់តែល្បីរន្ទឺដោយមានឈ្មោះថាជា **ស្តេចក្បាច់គុណ** ឬ **អធិទេព ក្បាច់គុណ**។ ដោយមានកេរ្តិ៍ឈ្មោះអាចប្រៀបផ្ទឹមទៅនឹង **ខុងជឺ** ដែលជា **ស្តេចអក្សរសាស្ត្រ** ឬ **អធិទេពអក្សរសាស្ត្រ** បាន ។ ដោសារ គាន់អ៊ី ធ្លាប់បានប្រទានឋានៈជាសីមឹងលុក ក្នុងការប្រឡងជ្រើសរើសមន្ត្រីរាជការនិងចេះព្យាបាលជំងឺ បំបាត់គ្រោះចង្រៃ បណ្តេញខ្មោចព្រាយ បិសាច និងឧបទ្រពចង្រៃ ដាក់ពិន័យនិងកាត់ទោសជនក្បត់ជាសកម្មជនឃ្លាំមើលត្រួតពិនិត្យថែមទាំងជាអ្នកជួយរកលាភសក្ការៈផ្សេងៗ ជាអ្នកនាំសំណាងនិងជាទេវតាថែរក្សាការពារ។ ដោយសារតែសមត្ថភាពនិងយុទ្ធសិល្ប៍គ្រប់មុខបែបនេះទើបបានជាប្រជារាស្ត្រដែលប្រកបរបរគ្រប់មុខទាំងអស់ ទាំងចាស់ទាំងក្មេង ទាំងស្រី ទាំងប្រុសសុទ្ធតែគោរពបូជាចំពោះ **គាន់ អ៊ី** ខ្លាំងណាស់ ៕





និស្សិតវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា
ធ្វើនំគាវទឹកក្នុងពិធីចូលឆ្នាំចិន (ឆ្នាំ២០១០)


| | | |
|---|---|---|
| អាសយដ្ឋាន | ៖ | មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ (ក្នុងរាជបណ្ឌិត្យសភាកម្ពុជា) |
| ទូរស័ព្ទ | ៖ | ០២៣ ៨៦៦ ១៥៦ |
| ទូរសារ | ៖ | ០២៣ ៨៦៦ ១៥៦ |
| សារអេឡិចត្រូនិក | ៖ | cheamunyrith@yahoo.com |
| គេហទំព័រ | ៖ | www.cirac.edu.kh |



**បោះពុម្ពលើកទី ១ ចំនួន ១.០០០ក្បាល**

9789996359514